# វិចារណកថា

កង្វះសមត្ថភាពជំនាញរបស់យុវជន គឺជាប្រធានបទនៃការសិក្សាអប់រំនាពេលបច្ចុប្បន្ន។ ក្នុងន័យនេះ សន្និសីទអន្តរជាតិដែលរៀបចំដោយ យូណេស្កូ បានដាក់ចេញនូវគោលគំនិតមួយចំនួនសម្រាប់ជួយយុវជនឱ្យមានសមត្ថភាពជំនាញ ឈានទៅរកការងារធ្វើបានសមស្របក្នុងសតវត្សទី២១។ គោលគំនិតទាំងនេះ មានជាអាទិ៖

- ការចូលរួមធ្វើការសម្រេចរបស់យុវជន (សមត្ថភាពយុវជនជាគោល)
- ប្រពលភាព (កំរិតសកម្មភាពដែលកើតឡើងជាលំដាប់)នៃអក្ខរកម្ម
- យុទ្ធសាស្ត្រថ្មីចំពោះគ្រូបង្រៀន។

១-សមត្ថភាពជំនាញរបស់យុវជន

ការបាត់បង់ការងារ ភាពគ្មានការងារធ្វើ ការប្រែប្រួលជាប្រចាំនៃទីផ្សារការងារ ការបដិសេធរបស់សង្គម ភាពក្រីក្រ ជាពិសេសកង្វះសមត្ថភាពជំនាញរបស់យុវជន គឺជាប្រធានបទអាទិភាពរបស់យូណេស្កូ ទាក់ទងនឹងការសិក្សាអប់រំ ការបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ។

សមាជអន្តរជាតិលើកទី៣ ឆ្នាំ២០១២ នៅសៀងហៃ (ប្រទេសចិន) ដែលជាការជួបសន្ទនាកំរិតពិភពលោកបានបង្ហាញ និងតម្រង់គោលដៅជំរុញ «ការបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈដើម្បីអភិវឌ្ឍសមត្ថភាពសម្រាប់ការងារនិងជីវភាព»។ ទន្ទឹមនឹងនេះ យើងត្រូវស្វែងយល់គ្រប់បញ្ហាប្រឈមដែលនាំឱ្យប្រព័ន្ធបណ្ដុះបណ្ដាលពុំអាចចូលរួមអភិវឌ្ឍសមត្ថភាព។ ប្រការនេះយើងត្រូវរកឱ្យឃើញមធ្យោបាយដើម្បីបង្កលក្ខណៈជាស្ពានរវាងសាលារៀន និងការងារម្យ៉ាង និងម្យ៉ាងទៀតយើងក៏ត្រូវកំណត់ទិសដៅយុទ្ធសាស្ត្រដើម្បីចាប់ដំណើរការប្រព័ន្ធបណ្ដុះបណ្ដាលតាមរយៈកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ ទាំងបច្ចេកទេស ទាំងហិរញ្ញវត្ថុផងដែរ។

របាយការណ៍របស់សមាជអន្តរជាតិលើកទី៣ គឺជាកម្លាំងជំរុញដើម្បីទាំងអស់គ្នាពិនិត្យឡើងវិញ កម្មវិធីសិក្សាក៏ដូចជាដាក់ចេញនូវច្បាប់កាតព្វកិច្ចសិក្សា និងការសិក្សាឥតបង់ថ្លៃ។

ដូចនេះ ការផ្ដល់ប្រឹក្សាចំពោះគោលនយោបាយអប់រំ ជំនួយដល់ដំណើរការនៃការសិក្សា និងការប្រឡង ជាពិសេសការប្រមូលទិន្នន័យទាក់ទងនឹងប្រព័ន្ធបណ្ដុះបណ្ដាល ទីផ្សារពលកម្ម ព្រមទាំងការត្រួតពិនិត្យវាយតម្លៃចំពោះប្រព័ន្ធបណ្ដុះបណ្ដាល គឺជាអ្វីដែលចាំបាច់ខ្វះមិនបាន។

២-ប្រពលភាព(កំរិតសកម្មភាពដែលកើនឡើងជាលំដាប់)នៃអក្ខរកម្ម

ការត្រួតពិនិត្យវាយតម្លៃលើការអនុវត្តកម្មវិធីអក្ខរកម្មបានបង្ហាញឱ្យឃើញពីឧបសគ្គនៃការរីកចម្រើន ពីបទពិសោធន៍ល្អជាវិជ្ជមានរបស់ដៃគូ (អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ស្ថាប័នឯកទេសអ.ស.ប.) ដែលជួយធ្វើឱ្យសម្រេចគោលដៅរំពឹងទុករបស់អក្ខរកម្មនាឆ្នាំ២០១៥។

ដើម្បីបន្តវឌ្ឍនភាពនៃដំណើរការរបស់កម្មវិធីអក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធប្រកបដោយគុណភាពយូណេស្កូ ធានានឹងបង្កលក្ខណៈផ្ដល់ជំនួយឧបត្ថម្ភដល់វិស័យនេះទាំងលើទិដ្ឋភាពបច្ចេកទេស ទាំងទិដ្ឋភាពហិរញ្ញវត្ថុ។

៣-យុទ្ធសាស្ត្រថ្មីចំពោះគ្រូបង្រៀន

ប្រធានបទសម្រាប់ទិវាអន្តរជាតិគ្រូបង្រៀនឆ្នាំ២០១២ ដែលយូណេស្កូ បានដាក់ចេញដោយផ្អែកលើបទពិសោធន៍យូរឆ្នាំ វិធីសាស្ត្រនិងគំនិតផ្ដួចផ្ដើម គឺយុទ្ធសាស្ត្រថ្មីពាក់ព័ន្ធនឹងគ្រូបង្រៀន សម្រាប់រយៈពេល៤ឆ្នាំពី២០១២ ដល់ ២០១៥ រួមមានអាទិភាព ៣ ជាចម្បង៖

- បំពេញកង្វះចំនួនគ្រូបង្រៀន
- កែលម្អគុណភាពនៃការបង្រៀន
- ជំរុញតួអង្គពាក់ព័ន្ធឱ្យយកចិត្តទុកដាក់លើការងារស្រាវជ្រាវ ការផ្ដល់ចំណេះដឹង ទំនាក់ទំនងជាមួយសាលារៀន...។

ក្នុងបរិបទនៃយុទ្ធសាស្ត្រថ្មី យើងឃើញមានប្រទេស ៣ មុនគេ ក្នុងតំបន់អាហ្វ្រិកបានអនុវត្តគម្រោង៤ឆ្នាំនេះ ទាក់ទងនឹងការងារអប់រំប្រកបដោយគុណភាព ដោយផ្ដើមពីការបណ្ដុះបណ្ដាលគ្រូបង្រៀន ក្រោមការគាំទ្របច្ចេកទេសហិរញ្ញវត្ថុរបស់យូណេស្កូ និងប្រទេសចិន។

នេះជាឧទាហរណ៍នៃកិច្ចសហប្រតិបត្តិការថ្មីរបស់អង្គការ «ត្បូង-ត្បូង» ដែលផ្ដោតលើប្រព័ន្ធបណ្ដុះបណ្ដាលគ្រូបង្រៀន ក្នុងន័យឈានទៅសម្រេចគោលដៅ «ការអប់រំសម្រាប់ទាំងអស់គ្នា» នាឆ្នាំ២០១៥។

ជារួម វិធានការសរុប (ក្របខ័ណ្ឌច្បាប់ ផែនការសកម្មភាព) និងមធ្យោបាយសរុប (បច្ចេកទេស-ហិរញ្ញវត្ថុ) ជាលក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីធ្វើឱ្យសម្រេចគោលដៅនៃការសិក្សាអប់រំក្នុងសតវត្សទី២១ ដោយជោគជ័យ៕

**គណៈកម្មាធិការគណ្ណាល**

# មតិស្វាគមន៍ និងរបាយការណ៍អបអរ

**Gasydæan$^3$ GaKaខួបទី ១៦ ទិវាគ្រូបង្រៀន ៥ តុលា (៥ តុលា ១៩៩៧- ៥ តុលា ២០១៣)**

**វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (១៤ តុលា ២០១៣)**

- សូមគោរពឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សូមគោរពលោកស្រី **អានឡឺម៉ៃត្រ** អ្នកតំណាងអង្គការយូណេស្កូ ប្រចាំព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិជាទីគោរព
- លោកគ្រូ អ្នកគ្រូ អង្គពិធីទាំងមូលជាទីមេត្រី

ជាបឋម ក្នុងពិធីដ៏មហោឡារិកនេះ យើងខ្ញុំសមាគមបុគ្គលិកសិក្សាខ្មែរ សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា សមាគមគ្រូបង្រៀនជាតិកម្ពុជា សមាគមអ្នកអប់រំជាតិដើម្បីអភិវឌ្ឍន៍ សមាគមគ្រូបង្រៀនខ្មែរ សូមគោរពជូនពរ និងអបអរសាទរយ៉ាងស្មោះអស់ពីដួងចិត្ត ជូនចំពោះឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** ក្នុងឱកាសដែលឯកឧត្តមត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាត្រាស់បង្គាប់តែងតាំងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃនេះ ជាទិវាដ៏ឧឡារិកអធិកអធមក្រៃលែង ដែលសមាគមយើងខ្ញុំទាំងឡាយមានកិត្តិយសចូលរួមពិធីអបអរសាទរទិវាគ្រូបង្រៀន ៥ តុលា ខួបទី១៦ ឆ្នាំ២០១៣នេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ យើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តម និងការយកចិត្តទុកដាក់ខ្ពស់របស់ឯកឧត្តមដែលបានឆ្លៀតឱកាសផ្អើមការងារថ្មីដ៏មមាញឹកអញ្ជើញមកជាអធិបតីក្នុងពិធីអបអរទិវាគ្រូបង្រៀន ៥ តុលា នាពេលនេះ និងសូមគោរពជូនពរស្វាគមន៍ ដោយក្ដីរីកើបសប្បាយរីករាយ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅក្រៃលែង។

ថ្ងៃនេះ រួមជាមួយពិភពលោកដែលបានប្រារព្ធទិវាគ្រូបង្រៀនក្រោមប្រធានបទ"យើងទាំងអស់គ្នាត្រូវការ គ្រូបង្រៀន" យើងសូមចូលរួមអបអរទិវាគ្រូបង្រៀន ៥ តុលា ២០១៣ នេះ ក្នុងស្ថានភាពដែលវិស័យអប់រំជាតិយើងកំពុងមានការរីកចម្រើនទាំងបរិមាណ និងគុណភាពគួរឱ្យកត់សម្គាល់ រួមនឹងតម្លៃសីលធម៌របស់សង្គមកំពុងមានការវិវត្តន៍ល្អប្រសើរឡើងជាលំដាប់។

ការសម្រេចបាននូវសមិទ្ធផលដ៏ឧត្តុង្គឧត្តមនេះ មិនអាចកាត់ផ្ដាច់បានពីការបំពេញបេសកកម្មដ៏ថ្លៃថ្លារបស់គ្រូបង្រៀនគ្រប់កំរិត ថ្នាក់ដឹកនាំគ្រប់ឋានានុក្រម ប្រកបដោយការទទួលខុសត្រូវ និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការរួមចំណែកបំពេញភារកិច្ចជាអ្នកអប់រំបណ្ដុះបណ្ដាល ជាអ្នកមានទេពកោសល្យ និងគរុវិជ្ជា ចិត្តសាស្ត្រក្នុងការបង្ហាត់បង្រៀនសិស្ស និស្សិត ទាំងផ្នែកអប់រំចំណេះទូទៅ ឧត្តមសិក្សា បណ្ដុះបណ្ដាលបច្ចេកទេស ឯកទេស អក្ខរកម្ម ទាំងផ្នែកអប់រំក្រៅប្រព័ន្ធប្រកបដោយជោគជ័យ។

ទន្ទឹមនឹងនេះ លោកគ្រូ អ្នកគ្រូក៏បានខិតខំសិក្សាស្រាវជ្រាវតាមរូបភាពស្វ័យសិក្សា និងការបណ្ដុះបណ្ដាលបន្តស្របតាមយុទ្ធសាស្ត្រអប់រំថ្មីដែលធានាការលើកកម្ពស់សមត្ថភាពបង្រៀន និងគុណតម្លៃនៃមុខងារគ្រូបង្រៀនឱ្យបានល្អប្រសើរជាបន្តបន្ទាប់។

ទោះជាយ៉ាងនេះក្ដី យើងក៏មិនគួរបំភ្លេចរំលឹកពីប្រវត្តិអប់រំរបស់កម្ពុជាយើងដែរ ដែលបានចាប់ផ្ដើមពីក្រោយថ្ងៃជ័យជំនះ ៧ មករា។ គ្រូបង្រៀន អ្នកចេះដឹង ត្រូវបានស្លាប់ និងកាប់សម្លាប់ស្ទើរគ្មានសល់។ យើងចាប់ផ្ដើមការសិក្សាក្រោមទិសស្លោក «អ្នកចេះ បង្រៀនអ្នកមិនចេះ» «អ្នកចេះច្រើនបង្រៀនអ្នកចេះតិច»។ គ្រូបង្រៀនជាគ្រូចាត់តាំងពុំទាន់មានការបណ្ដុះបណ្ដាល ហើយនៅកន្លែងខ្លះគ្រូបង្រៀនត្រូវបានរៀនតែមួយ ឬពីរមេរៀនប៉ុណ្ណោះមុននឹងយក

មេរៀននោះទៅបង្រៀនសិស្សបន្ត។ ក្រោយមកទើបមានរូបមន្តបណ្តុះបណ្តាលគ្រូ ៧+១ គ្រូបឋម ៧+៣ គ្រូមធ្យមសិក្សាកំរិត១ និងការធ្វើក្រឹតការជាបន្តបន្ទាប់។ ឯរបបឧបត្ថម្ភវិញ គឺអង្ករ១៦គីឡូក្រាមក្នុង ១ខែ ជាអង្ករចាស់ផ្អារ ជង្គរុំដែលយើងច្រើនហៅថា អង្ករនាងអួ អង្ករនាងរុំជាដើម ទំរាំបានមករៀនចាយលុយប្រាក់ខែ៦០រៀលរហូត១០០រៀល ១២០រៀល។ ឯថ្នាក់រៀនទៀតសោត គឺតាមរោងគោ ក្រោមផ្ទះ ក្នុងវត្តអារាម ឬរោងបណ្តោះអាសន្នទៅតាមគ្រប់លទ្ធភាព...។

មើលឃើញការលំបាកហួសវិស័យបែបនេះ ទើបយើងដឹងថា ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំគ្រូបង្រៀនយើងក្នុងភារកិច្ចជាអ្នកអប់រំបណ្តុះបណ្តាល ជាអ្នកគតុកោសល្យបានខិតខំប្រឹងប្រែងតស៊ូ ដោយអំណត់ព្យាយាម និងក្តីស្រឡាញ់យ៉ាងស្មោះ ដើម្បីផ្ទេរចំណេះដឹងដែលជាតម្លៃនៃវិទ្យាសាស្ត្រ បច្ចេកទេស អាកប្បិរិយាឥរិយាបថ ចរិយាធម៌ សីលធម៌ សង្គមធម៌ចំពោះកុមារា កុមារី សិស្ស និស្សិតទាំងឡាយដោយគ្មានលាក់លៀម គ្មានរើសអើងរហូតមកស្របតាមគំនិតថ្មី នៃការអប់រំ គឺរៀនដើម្បីចេះ រៀនដើម្បីធ្វើ រៀនដើម្បីមានសីលធម៌ល្អ និងរៀនដើម្បីរួមរស់សុខដុមជាមួយគ្នា។

ដើម្បីជាកិត្តិយសដ៏ឧត្តុង្គឧត្តមដល់គ្រូបង្រៀនកម្ពុជា និងរក្សាបាននូវប្រពៃណីដ៏ល្អផូរផង់ ពាក់ព័ន្ធនឹងវប្បធម៌គោរពស្រឡាញ់ និងដឹងគុណគ្រូបង្រៀន នាឆ្នាំ១៩៩៧ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យកថ្ងៃ ៥ តុលា ជាទិវាគ្រូបង្រៀននៃព្រះរាជាណាចក្រកម្ពុជា និងបានឧទ្ទិសឱ្យទិវាគ្រូបង្រៀន ៥ តុលា ជាទិវាដឹងគុណគ្រូបង្រៀនជារៀងរហូត។

មកដល់ឆ្នាំ២០១៣ នេះ ទិវាគ្រូបង្រៀនកម្ពុជា ៥ តុលា មានអាយុ១៦ឆ្នាំហើយដែលបានញ៉ាំងឱ្យប្រជាជនកម្ពុជាគ្រប់ជាន់ថ្នាក់កាន់តែចាប់អារម្មណ៍ និងគាំទ្រទាំងកាយ-ចិត្តខ្លាំងថែមទៀតចំពោះប្រពៃណីដ៏ល្អផូរផង់ក្នុងមនោសញ្ចេតនាស្រឡាញ់គោរពដឹងគុណ និងចាត់ទុកគ្រូបង្រៀនថាជាអ្នកបណ្តុះបណ្តាលផ្នែកសីលធម៌គុណធម៌ និងចំណេះវិជ្ជាដូចឪពុកម្តាយចំពោះបុត្រធីតារបស់ខ្លួនផ្ទាល់។ គ្រូបង្រៀនពិតជាវិស្វករព្រលឹងជាតិ ជាស្ថាបនិកធនធានមនុស្សដែលជាធនធានចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ។

យើងខ្ញុំសមាគមបុគ្គលិកសិក្សាខ្មែរ សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា សមាគមគ្រូបង្រៀនជាតិកម្ពុជា សមាគមអ្នកអប់រំជាតិដើម្បីអភិវឌ្ឍន៍ សមាគមគ្រូបង្រៀនខ្មែរ សូមយកឱកាសដ៏ប្រពៃថ្លៃថ្លានេះ សំដែងជាថ្មីនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងគាំទ្រយ៉ាងពេញទំហឹងចំពោះរាជរដ្ឋាភិបាលអណត្តិទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោដែលតែងតែគិតគូរដល់ជីវភាពរបស់មន្ត្រី រាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កម្មករនិយោជិកទាំងរដ្ឋ ទាំងឯកជន ជាពិសេសការអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

យើងខ្ញុំសូមប្តេជ្ញាខិតខំរួមចំណែកបន្តទៀត ក្នុងការលើកកម្ពស់កិត្តិយសគ្រូបង្រៀនតាមគ្រប់មធ្យោបាយក្នុងការលើកកម្ពស់គុណភាពតម្លៃវិជ្ជាជីវៈ ក្រមសីលធម៌ វិជ្ជាជីវៈគ្រូបង្រៀន សមត្ថភាពវិជ្ជាជីវៈ បច្ចេកទេស មុខជំនាញ ចិត្តគរុកោសល្យ ទាំងខាងផ្លូវចិត្ត ទាំងខាងសម្ភារៈ ដើម្បីធ្វើយ៉ាងណាឱ្យគ្រូបង្រៀនកាន់តែសក្តិសមថែមទៀត ជាអ្នកដែលគេត្រូវដឹងគុណមិនអាចបំភ្លេចបាន។

សូមចូលរួមជាមួយសង្គមជាតិទាំងមូល រក្សាការពារទម្លាប់គោរពស្រឡាញ់ដឹងគុណគ្រូបង្រៀនឱ្យស្ថិតនៅរស់រវើកជានិច្ចក្នុងបេះដូងរបស់យើងទាំងអស់គ្នា។ សូមស្មារតីទិវា ៥ តុលា ស្ថិតស្ថេរជានិច្ច និងសូមនាំមកនូវសព្ទសាធុការពរជូនលោកគ្រូ អ្នកគ្រូ សូមបានសម្រេចនូវអ្វីដែលល្អប្រសើរបំផុតសម្រាប់អាជីពជាគ្រូបង្រៀន។

សូមគោរពជូនពរ ឯកឧត្តមរដ្ឋមន្ត្រី និងអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងឡាយ ៤ ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរគុណ!**

# ច្បាប់ស្តីពីការអប់រំ (ត)

-ខិតខំសិក្សាឱ្យអស់ពីលទ្ធភាពរបស់ខ្លួន ដើម្បីទទួលបានការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាព បញ្ញា និងសេចក្ដីថ្លៃថ្នូរ ។

**មាត្រា ៣៦.- សិទ្ធិ និងករណីយកិច្ចរបស់មាតាបិតា ឬ អ្នកអាណាព្យាបាល**

សិទ្ធិរបស់មាតាបិតា ឬ អ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជន ដែលស្ថិតក្នុងបន្ទុកមានដូចតទៅ :

-សិទ្ធិក្នុងការជ្រើសរើសកម្មវិធីអប់រំ និងគ្រឹះស្ថានសិក្សា សម្រាប់អ្នកសិក្សាឱ្យចូលសិក្សា

-សិទ្ធិទទួលបានព័ត៌មាន និងរបាយការណ៍នៃការសិក្សាពីគ្រឹះស្ថានសិក្សារបស់អ្នកសិក្សា ដែលស្ថិតក្នុងបន្ទុក

-សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញ នៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់សាលារៀន និងថ្នាក់ជាតិ ដោយផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួន ។

ករណីយកិច្ចមាតាបិតា ឬ អ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជនដែលស្ថិតក្នុងបន្ទុក :

-នាំកុមារដែលមានអាយុចាប់ពី ៦ (ប្រាំមួយ)ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០ (ចិតសិប)ខែ ឡើងទៅចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១ នៃកម្មវិធីអប់រំកំណោះទូទៅនៅសាលារៀន ដែលមានអាជ្ញាប័ណ្ណអប់រំ

-ខិតខំឱ្យអស់លទ្ធភាព ដើម្បីគាំទ្រការសិក្សារបស់អ្នកសិក្សាជាពិសេសចំពោះការអប់រំកម្រិតមូលដ្ឋាន

-យកចិត្តទុកដាក់ផ្សារភ្ជាប់សាលា គ្រួសារ និងសហគមន៍ ដើម្បីចូលរួមជួយបណ្ដុះបណ្ដាល និងកែលម្អបរិស្ថានសិក្សា ។

**មាត្រា ៣៧.- សិទ្ធិ និងករណីយកិច្ចរបស់បុគ្គលិកអប់រំ**

សិទ្ធិរបស់បុគ្គលិកអប់រំមានដូចតទៅ :

-សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ខ្ពស់ពីសង្គម

-សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈ

-សិទ្ធិបង្កើត ឬ ចូលរួមក្នុងសមាគមបុគ្គលិកអប់រំ ឬ សមាគមវិជ្ជាជីវៈផ្សេង[illegible]កំណត់ជាធរមាន

-សិទ្ធិរៀបចំការប្រជុំលើការងារអប់រំ ជាសាធារណៈ

-សិទ្ធិចូលរួមនៅក្នុងកិច្ចការនយោបាយតាមច្បាប់កំណត់

-សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដោយផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួន

-សិទ្ធិទទួលសេវាអប់រំផ្សេងទៀតប្រកបដោយសមធម៌ និងសិទ្ធិផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។

កាតព្វកិច្ចរបស់បុគ្គលិកអប់រំ :

-គោរពក្រមសីលធម៌វិជ្ជាជីវៈ

-បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ជាធរមាន

-អនុវត្ត និងអភិវឌ្ឍការងាររបស់ខ្លួនដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ។

បុគ្គលិកអប់រំឯកជនមានសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតដូចមានចែងក្នុងច្បាប់ស្តីពីការងារជាធរមាន ។

## មាត្រា ៣៨.- ការអប់រំពិសេស

រដ្ឋលើកទឹកចិត្ត និងជំរុញឱ្យមានការអប់រំពិសេស សម្រាប់ជនពិការ និង អ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/ ឬ បញ្ញាខ្ពស់ ។

ការអប់រំពិសេស ផ្តល់ចំពោះអ្នកសិក្សាពូកែឱ្យស្របតាមបញ្ញា និងទេពកោសល្យរបស់អ្នកសិក្សានោះ និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាពិការអាចសិក្សាបានដោយសមរម្យ ។

កម្មវិធីអប់រំពិសេស ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

## មាត្រា ៣៩.- សិទ្ធិរបស់អ្នកសិក្សាពិការ

អ្នកសិក្សាពិការមានសិទ្ធិដូចអ្នកសិក្សាមិនពិការដែរ និងមានសិទ្ធិពិសេសដោយឡែកផ្សេងទៀត :

-អ្នកសិក្សាពិការទាំងពីរភេទមានសិទ្ធិសិក្សាជាមួយសិស្ស ឬ និស្សិតទូទៅបាន ប្រសិនបើមានការសម្របសម្រួលសមស្របក្នុងដំណើរការសិក្សា ដែលអ្នកសិក្សាពិការនោះអាចអនុវត្តតាមកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សានោះបាន

-អ្នកសិក្សាពិការដែលមានសេចក្តីត្រូវការពិសេស មានសិទ្ធិទទួលបានការ

(នៅមាន ត)




## ចម្រៀង និងសារប្រយោជន៍

ដោយយល់ឃើញពីសារប្រយោជន៍នៃចម្រៀងរបស់ខ្មែរយើងដែលមានតាំងពីយូរលង់ណាស់មកហើយ និងដើម្បីថែរក្សាឱ្យគង់វង្សក្នុងមនោសញ្ចេតនាអភិរក្សវប្បធម៌របស់ជាតិយើង ព្រមទាំងរំឭកឡើងវិញនូវស្នាដៃនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ ដែលលោកបានចងក្រងទុកមក។ លោកបណ្ឌិត **ចាប ពិន** បានបន្សល់ទុកនូវស្នាដៃជាច្រើនសម្រាប់កូនខ្មែរជំនាន់ក្រោយ។

តាមការស្រាវជ្រាវ ខ្ញុំសូមបរិយាយអំពីកំណើតចម្រៀង និងផលប្រយោជន៍ចម្រៀងដូចតទៅនេះ៖

សួរៈ តើការច្រៀងកើតពីពេលណាមក?

ឆ្លើយៈ ការច្រៀងកើតតាំងពីពេលមនុស្សចេះប្រើពាក្យសំដី។

សួរៈ ហេតុអ្វីបានជាប្រជាជនចូលចិត្តច្រៀង?

ឆ្លើយៈ បានជាប្រជាជនចូលចិត្តច្រៀង ព្រោះត្រូវការរស់ក្នុងសង្គម ត្រូវការចិញ្ចឹមបុត្រ ត្រូវការគូសង្សារ ត្រូវការអាពាហ៍ពិពាហ៍ជាដើម។

សួរៈ តើការច្រៀងជាការសម្ដែងពីអ្វី?

ឆ្លើយៈ ការច្រៀងជាការសម្ដែងពីសាវតារជាតិ ទឹកចិត្តអធ្យាស្រ័យ និងបំណងរបស់ប្រជាជន គឺថាប្រជាជនមានបំណងយ៉ាងណាក៏ដោយ ក៏បណ្ដាលឱ្យច្រៀងតាមទំនងបំណងនោះ រួមសេចក្ដីថា ចម្រៀងជាសំឡេង ឬជាសម្រែកចិត្តរបស់មនុស្សពិតៗ ទោះបីអ្នកមិនចេះតែងទំនុកខ្លួនឯង ក៏រមែងជ្រើសរើសយកទំនុកចាស់ៗរបស់គេដែលអ្នកផងតែងច្រៀងមកច្រៀងតម្រូវតាមសេចក្ដីត្រូវការរបស់ខ្លួន។ មិនមែនចំពោះតែមនុស្សនោះទេ សូម្បីតែសត្វស្លាបខ្លះ ដូចជាសេក សារិកាជាដើម តាមធម្មតាវាច្រៀងជាសម្រែកចិត្តរបស់វា ឬចំពោះគូសង្សាររបស់វាដែរ ព្រោះគេតែងឃើញវានៅក្បែរគ្នា ធ្វើមុខមាត់ផ្ទៀងផ្ទង់ផ្ដោះផ្ដងរកគ្នា ដោយសំឡេងដ៏ពីរោះគ្រលួចគួរឱ្យស្រងេះស្រងោច។

ប្រជាជនគ្រប់ជាតិ គ្រប់ភាសា គ្រប់ប្រទេស ក្នុងសាកលលោក ទាំងសម័យបុរាណ ទាំងសម័យបច្ចុប្បន្ន ទាំងប្រទេសរីកចម្រើនហើយ ទាំងប្រទេសមិនទាន់រីកចម្រើន សុទ្ធតែនិយម ការច្រៀងទាំងអស់ សូម្បីតែពេលអនាគតក៏ដូច្នេះដែរ។ ប្រទេសដែលរីកចម្រើនខ្លាំងក៏គេរឹតតែត្រូវការណាស់ទៅទៀត។ ដោយហេតុថាប្រជាជនក្នុងសាកលលោកនិយមចម្រៀងគ្រប់រូប បានជាគេហៅចម្រៀងគ្រប់បែបថា «ចម្រៀងប្រជាប្រិយ» ប្រែថា «ចម្រៀងជារបស់ដែលប្រជាជនរាប់អាន»។

ទំនុកច្រៀងប្រជាប្រិយមានភាពផ្សេងៗគ្នាប្រព្រឹត្តទៅតាមស្ថានភាពនៃសញ្ជាតិនៃប្រទេស និងសង្គមរបស់ប្រជាជនប្រហែលគ្នានឹងជីវភាពរបស់ប្រជាជាតិក្នុងសាកលលោក ដែលប្លែកៗគ្នា ដោយបែបៗតែជារួមក្នុងបទជាសំឡេង ឬសម្រែកចិត្តរបស់ប្រជាជនប្រចាំជាតិនីមួយៗមានដូចគ្នា។

ចម្រៀងជាគូនឹងភ្លេង ជាសិល្បៈមួយផ្នែកហៅថា គីតសាស្ត្រ[១] ជាអារ្យធម៌ ឬជាគ្រឹះដ៏សំខាន់ប្រចាំសញ្ជាតិ ហើយជាដំហររបស់ប្រជាជាតិនីមួយៗ អាចញ៉ាំងជាតិឱ្យគង់វង្សដូចភាសា និងអក្សរសាស្ត្រដែលអាចធ្វើជាតិឱ្យបិតបេរចីរកាលនៅក្នុងលោក។

តាមពិតភាសា អក្សរ ចម្រៀង ភ្លេងរបស់ជាតិណា ជាគ្រឿងសម្គាល់ដ៏សំខាន់សំរាប់ជាតិនោះ គឺគេគ្រាន់តែឃើញអក្សរ ឮភាសាចម្រៀង ឬភ្លេងរបស់ជាតិណា គេអាចស្គាល់បានភ្លាមថា អក្សរ ភាសា ចម្រៀង ភ្លេង របស់ជាតិនោះបានជាប្រាកដ មិនបាច់ឃើញរូបមនុស្សជាម្ចាស់របស់ឡើយ។

ចម្រៀងខ្មែរ ជាអារ្យធម៌ ជាគ្រឹះ ហើយជាគីតសិល្បៈដ៏សំខាន់មួយផ្នែករបស់ខ្មែរសម្រាប់ឧបត្ថម្ភជាតិខ្មែរឱ្យចាក់ឫសជាប់ស្ថិតស្ថេរប្រាកដជាប្រជាជាតិនៅក្នុងលោក គឺថាចម្រៀងខ្មែរមាននៅក្នុងលោកដរាបណាជាតិខ្មែរក៏មាននៅក្នុងលោកដរាបនោះ បើចម្រៀងខ្មែររលាយសូន្យបាត់ទៅវេលាណាខ្មែរក៏បាត់ទៅវេលានោះជាប្រាកដ។ ហេតុនេះ ខ្មែរយើងគួរស្គួនគ្រងរក្សាកត់ត្រាទុកនូវចម្រៀងខ្មែរ ដែលមានបែបបទ និងទំនុកច្រៀងផ្សេងៗឱ្យគង់នៅតទៅកុំឱ្យបាត់បង់។

តាមពិត ចម្រៀងប្រជាប្រិយខ្មែរ មានតាំងពីមានខ្មែរនៅក្នុងលោកនេះមកម្ល៉េះ។ ប៉ុន្តែការផ្លាស់ប្ដូរសម័យរបស់ប្រទេសខ្មែរដូចជាផ្លាស់ពីសម័យអង្គរមកជាសម័យបច្ចុប្បន្នជាដើមតែងធ្វើចម្រៀងខ្មែរឱ្យផ្លាស់ប្ដូរពាក្យពេចន៍ក្នុងទំនុកចាស់ខ្លះឱ្យបង្កើតជាទំនុកថ្មីខ្លះ សម្រួលទៅតាមសម័យរបស់ខ្លួនជាធម្មតា ដើម្បីឱ្យប្រជាជនខ្មែរក្នុងសម័យខ្លួនស្ដាប់បានដោយងាយ។

ខាងក្រោមនេះខ្ញុំសូមស្រង់យកដោយសង្ខេបតាមដែលចាំបានខ្លះនូវទំនុកច្រៀងចាស់របស់ខ្មែរដែលមិនដឹងជាតែងក្នុងសម័យណានិងមិនដឹងជារបស់អ្នកនិពន្ធណា ឬផ្ដើមច្រៀងមុនគេនោះមកកត់ត្រាទុកជាឧទាហរណ៍ក្នុងទីនេះតាមបទ និងទំនុកច្រៀងមានប្រការផ្សេងៗដែលជាសំឡេង ឬសម្រែកចិត្តរបស់ប្រជាជនជាតិខ្មែរសុទ្ធៗ ដើម្បីរក្សាទុកនូវទំនុកច្រៀងប្រជាប្រិយខ្មែរសម័យបុរាណឱ្យបានបិតបេរគង់វង្សតទៅ និងដើម្បីទុកជូនអស់លោកបងប្អូនរួមជាតិពិចារណាដូចតទៅនេះ:

**ទំនុកសំដែងសេចក្ដីខ្មាស**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលចង់បានស្ត្រីណាម្នាក់ តែមានគេមកដែងភាត់មុខយកបានទៅ ក៏បណ្ដាលឱ្យច្រៀងសម្ដែងទឹកចិត្តអៀនខ្មាស មានដើមថា:

ស្រីអើយ!បងប៉ង    មានគេដែងបង
បងមិនចង់នៅស្រុក    ស្លាប់ទៅជាខ្មោច
ដេកដីស្រណុក    បងមិនចង់នៅស្រុក
ខ្មាសមុខប្អូនស្រី។

**ទំនុកសំដែងសេចក្ដីស្ដាយ**

ទំនុកច្រៀងមួយបែបទៀត ជាសម្រែកចិត្តរបស់បុរសដែលខ្លួនបានចំណាំស្ត្រីណាម្នាក់ទុកតាំងពីក្មេងមក តែដល់ធំឡើងមានគេមកយកស្ត្រីនោះកាត់មុខបានទៅ ក៏បណ្ដាលឱ្យច្រៀងសំដែងទឹកចិត្តសោកស្ដាយមានដើមថា:

ស្ដាយអើយ    សែនស្ដាយ!    ដូចចេកនួនភ្លាយ    ស្រគាលទុំដើម។
បងខំស្រោចទឹក    តាំងពីតូចនៅ    ដល់ធំឡើងទៅ    នរណាបេះបាត់។

**ទំនុកសម្ដែងសេចក្ដីអាណិត និងសេចក្ដីរ៉ាប់រង**

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលស្រឡាញ់ស្ត្រីណាហើយ ឃើញស្ត្រីនោះធ្វើការនឿយហត់ មានចិត្តអាណិត ក៏បណ្ដាលឱ្យច្រៀងសម្ដែងសេចក្ដីអាណិត និងសេចក្ដីរ៉ាប់រង មានដើមថា:

ស្រីខ្មៅដើរឱន!    ដាក់មុខស្រពោន
ខ្មៅបងនឿយណាស់    បើជិតទៅរ៉ា
បងទៅជួយផ្លាស់    ខ្មៅបងនឿយណាស់
ដកផងស្ទូងផង។

(នៅមានត)

ដកស្រង់ដោយលោក **ខែម ធាន**

---

[១]គីតសាស្ត្រ : ក្បួនតម្រាដែលនិយាយពីចម្រៀង ឬទំនុកច្រៀង ក្បួនចម្រៀង។

# ប្រវត្តិនៃការអប់រំក្នុងពិភពលោក (ត)

**ឃ-ប្រព័ន្ធវណ្ណៈ**

វណ្ណៈដែលជាប្រភពដើមមាន ៤ គឺៈ

- ព្រាហ្មណៈ (Brahmins) : អ្នកអប់រំដែលជាបព្វជិត។
- ក្សត្រិយៈ (Kshatriyas) : អ្នកគ្រប់គ្រង ចៅក្រម និងអ្នកចម្បាំង ។
- វៃស្យៈ (Vaishyas) : ពាណិជ្ជករ។
- សូទ្រៈ (Sudras) : កសិករ។

ស្រទាប់វណ្ណៈក្រោមគេបំផុត គឺអ្នកដែលគេមិនឱ្យប៉ះពាល់ ដែលធ្វើការងារថោកទាបបំផុត។ ចល័តភាពសង្គមមិនមានទាល់តែសោះ។ មនុស្សនៅតែស្ថិតក្នុងវណ្ណៈដដែលតាំងពីពេលដែលគេបានកើតមក ហើយបានរៀនសូត្រនូវករណីកិច្ច និងតួនាទីរបស់ខ្លួន ដោយគ្រាប់តាមឪពុកម្តាយ និងមនុស្សចាស់ផ្សេងទៀត។ ការសិក្សាអប់រំ ទុកឱ្យតែមនុស្សវណ្ណៈខ្ពស់តែប៉ុណ្ណោះ ជាពិសេសគឺពួកព្រាហ្មណៈ។ ដោយចាត់ទុកថា ការរើសអើងវណ្ណៈជាការខុសច្បាប់ ឥណ្ឌាសម័យទំនើប បានបង្កឱ្យមានសកម្មភាពវិជ្ជមានសម្រាប់សមាជិកវណ្ណៈទាប។ ទោះជាយ៉ាងនេះក្តី ការរើសអើងនៅតែកើតមាន។

**៣-១ ការវិវឌ្ឍនៃការអប់រំឥណ្ឌា**

ការអប់រំនៅឥណ្ឌា ឆ្លុះបញ្ចាំងនូវតំរូវជាប្រវត្តិសាស្ត្រទូទៅនៃការរស់នៅ លាយឡំនឹងវប្បធម៌ផ្សេងៗគ្នា។ សាលារៀនសម័យដើម បានឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរវប្បធម៌ ដែលបាននាំមកដោយពួកអារ្យ៉ន។ ឥណ្ឌាបុរាណមានប្រភេទសាលារៀនដូចតទៅៈ

**ក-បទៈ**

- សាលារៀនពួកព្រាហ្មណ៍ សម្រាប់វណ្ណៈបព្វជិត សង្កត់ធ្ងន់ទៅលើសាសនាទស្សនវិជ្ជា។ វេទ និងឧបនិស័ទសៀវភៅសាសនាដ៏ពិសិដ្ឋរបស់ព្រាហ្មណ៍ ពណ៌នាគោលដៅនៃជីវិត ថាជាការស្រាវជ្រាវសច្ចភាពខាងស្មារតីសកល។ ការស្វែងរកសច្ចភាពដែលអ្នកអប់រំឥណ្ឌាជឿជាក់នោះ គឺថាការទាមទារឱ្យមានការតាំងការនាដ៏មានន័យ។ ការតាំងការនាអព្ភោហារិក[១]សម័យទំនើប និងយោគៈ ធ្វើតាមគោលការណ៍ឥណ្ឌាបុរាណ ដើម្បីស្វែងរកសច្ចភាព និងភាពស្ងប់ស្ងាត់ខាងស្មារតី។
- Tols គឺជាសាលារៀនដែលមានតែមួយបន្ទប់ ដែលមានតែគ្រូបង្រៀនតែម្នាក់បង្រៀនសាសនា និងច្បាប់។
- សាលារៀនវាំង ទទួលខុសត្រូវដោយព្រះអង្គម្ចាស់ បង្រៀនអក្សរសាស្ត្រច្បាប់ និងរដ្ឋបាល។

**ខ-សាលារៀន និងការបង្រៀន**

ទស្សនវិជ្ជាអប់រំឥណ្ឌា ដោយបានសង្កត់ធ្ងន់ទៅលើសាសនា បានបញ្ញត្តទំនាក់ទំនងគ្រូ-សិស្សយ៉ាងសមរម្យ។ គ្រូត្រូវតែលើកទឹកចិត្តសិស្សឱ្យចេះគោរពជីវិត និងចេះស្រាវជ្រាវរកសច្ចភាព។ សិស្សត្រូវតែគោរពគ្រូ ដែលជាប្រភពនៃគតិបណ្ឌិត ហើយគ្រូត្រូវតែចេះទប់អារម្មណ៍ កុំធ្វើឱ្យអាម៉ាស់មុខ។

គ -Mughuls

សន្តតិវង្ស Mughuls ដែលបង្កើតឡើងក្រោយពេលមានការចូលលុកលុយនៃពួកមូស្លីមបាននាំមកនូវសាសនា

(១) អព្ភោហារិក : គឺអ្វីៗដែលប្រាកដជាមាន ប៉ុន្តែល្អិតណាស់ កំបាំងណាស់ពិបាកនិយាយប្រាប់គ្នា។
ឧ៖ដូចជាសុរាដែលគេដាក់តិចតួចក្នុងសម្លរ៉ូជាគ្រឿងកាត់ចម្លាបជាអព្ភោហារិក។

អ៊ីស្លាម និងទស្សនវិជ្ជាពួក Persian និងអារ៉ាប់ វិទ្យាសាស្ត្រ អក្សរសាស្ត្រ តារាសាស្ត្រ គណិតវិទ្យា វេជ្ជសាស្ត្រ សិល្បៈ តន្ត្រី និងស្ថាបត្យកម្ម។

**ឃ-ការចូលមកដល់នៃពួកអង់គ្លេស**

ត្រឹមពេលដែលជនជាតិអង់គ្លេស បានចូលមកដល់ប្រទេសឥណ្ឌានៅចុងសតវត្សទី១៨ សាលារៀនរបស់ពួកឥណ្ឌាដឹកនាំដោយពួកហិណ្ឌូ ឬមូស្លីម ឬដោយនិកាយតូចៗ ដូចជាពុទ្ធសាសនិក Jains និង Parsis។ មានតែ១០% នៃកុមារឥណ្ឌា ភាគច្រើនក្មេងប្រុសបានចូលរៀន។ សាលារៀនជាន់ខ្ពស់ឥណ្ឌា ដឹកនាំដោយពួកព្រាហ្មណ៍ដោយសង្កត់ធ្ងន់លើអក្សរសិល្ប៍ខាងសាសនា គណិតវិទ្យា តារាសាស្ត្រ និងវេយ្យាករណ៍សំស្ក្រឹត។ សាលារៀនពួកមូស្លីមហៅថា Madrassahs ត្រូវបានផ្សារភ្ជាប់ទៅនឹងព្រះវិហារម៉ូស ហើយនិងសង្កត់ធ្ងន់ទៅលើវេយ្យាករណ៍ និងគម្ពីរកូរ៉ាន។

នៅពេលដែលចក្រភពអង់គ្លេសបានបង្កើតការគ្រប់គ្រងតាមបែបអាណានិគមនៅក្នុងប្រទេសឥណ្ឌា ពួកគេបានប៉ះទង្គិចនឹងអរិយធម៌ ជាមួយនឹងភាសា និងសាសនាជាច្រើន។ ពួកអង់គ្លេសដោយឱ្យតម្លៃទៅលើភាសាអង់គ្លេសជាងភាសាកំណើតរបស់ឥណ្ឌា បានបង្កើតភាសាអង់គ្លេសជាភាសាផ្លូវការសម្រាប់រដ្ឋាភិបាល និងពាណិជ្ជករ ហើយនិងបានបង្កើតសាលារៀន ដែលប្រើប្រាស់ភាសាអង់គ្លេស ដើម្បីបណ្តុះបណ្តាលជនជាតិឥណ្ឌា សម្រាប់មុខតំណែងនៅក្នុងសេវាកម្មស៊ីវិល ដែលគ្រប់គ្រងដោយជនជាតិអង់គ្លេស។

**៣-២ ការរួមចំណែករបស់ឥណ្ឌា ចំពោះការអប់រំពិភពលោក**

កេរដំណែលរបស់ឥណ្ឌាបុរាណចំពោះពិភពលោក គឺជាគំរូនៃរបៀបអប់រំអាចជួយដល់អរិយធម៌មួយអស់រយៈពេលជាច្រើនសតវត្ស។ តាមរយៈការធ្វើឱ្យជ្រួតជ្រាបវប្បធម៌ និងការសម្របសម្រួលឡើងវិញនោះ អរិយធម៌ឥណ្ឌាបានស្ថិតនៅរហូតដល់បច្ចុប្បន្ន។ នៅក្នុងបរិយាកាសសព្វថ្ងៃដែលមានភាពតានតឹងខាងសាសនា និងជាតិសាសន៍ដែលចេះតែមានការកើនឡើងនោះ ឥណ្ឌាបានប្រឈមមុខនឹងការប្រឆាំងយ៉ាងខ្លាំងក្នុងការធ្វើឱ្យជ្រួតជ្រាប និងគោរពវប្បធម៌ផ្សេងៗ។ សហរដ្ឋអាមេរិកនិងជាតិដែលមានពហុភាពខាងវប្បធម៌ផ្សេងៗប្រឈមមុខនឹងការប្រឆាំងដូចៗគ្នា។ ស្ថានភាពរបស់ឥណ្ឌាបានលាតត្រដាងពីរបៀបដែលវណ្ណៈ ដូចជាជាតិសាសន៍និយមក្នុងសហរដ្ឋអាមេរិក ត្រូវបានធ្វើឱ្យមាននិរន្តរភាពដោយសង្គម និងការអប់រំ ប៉ុន្តែឥឡូវនេះកំពុងត្រូវបានកែលំអ តាមរយៈលំនាំការអប់រំ។ លោកអ្នកក្នុងនាមជាគ្រូបង្រៀនម្នាក់ទំនងជានឹងត្រូវបានប្រឆាំងតាមភាពផ្សេងៗនៃសិស្សរបស់អ្នក។ តើអ្នកនឹងប្រើពហុវប្បធម៌និយមជាមធ្យោបាយជំរុញភាពផ្សេងៗគ្នាខាងវប្បធម៌ក្នុងថ្នាក់រៀនរបស់អ្នកឬទេ?

(នៅមានត)

អនុបណ្ឌិត ស៊ូ សុធីរ

អ្វីដែលយើងគ្រាន់តែឮ យើងនឹងភ្លេច
អ្វីដែលយើងបានឃើញ យើងនឹងចាំ
អ្វីដែលយើងបានធ្វើ យើងនឹងចេះ។
ខុងជឺ



# ចិត្តវិទ្យាអប់រំ

## ការបណ្តុះចិត្តទៅជាសកម្មភាព

**I-សញ្ញាណទូទៅនៃសាលារៀន**

សាលារៀនជាគ្រឹះស្ថានអប់រំដែលមានតួនាទីបណ្តុះបណ្តាលមនុស្សឱ្យក្លាយទៅជាពលករប្រកបដោយសីលធម៌ គុណធម៌ និងសមត្ថភាពដែលអាចឆ្លើយតបទៅនឹងតម្រូវការកសាង និងអភិវឌ្ឍសង្គម។

ទស្សនៈខ្លះៗស្តីពីជីវិតចិត្តរបស់មនុស្ស

ក-នៅក្នុងចិត្តវិទ្យាកាលពីជំនាន់ដើម គេចាត់ទុកបាតុភូតចិត្តរបស់មនុស្សជាលទ្ធផលនៃមរតករបស់មនុស្សជំនាន់មុន ដែលបន្សល់ទុកឱ្យដល់មនុស្សជំនាន់ក្រោយ។

តាមទស្សនៈនេះ បញ្ហាបណ្តុះបណ្តាលនឹងអភិវឌ្ឍបាតុភូតចិត្តរបស់កុមារ មិនត្រូវបានលើកយកមកដោះស្រាយទេ។ នាទីសំខាន់របស់សាលារៀន គឺហ្វឹកហ្វឺនសិស្សឱ្យមានសម្បទា និងទម្លាប់ដើម្បីធ្វើជាអ្នកគ្រួតត្រា ឬអ្នកបម្រើ ព្រោះវាសនាអនាគតរបស់មនុស្សត្រូវបានកំណត់ជាមុនហើយស្រេច ដោយធាតុតំណពូជ។

ឧទាហរណ៍: កូនកសិករនៅតែជាកសិករ កូនមន្ត្រីនឹងក្លាយជាមន្ត្រី...។

ខ-បុគ្គលិកលក្ខណៈ និងតម្លៃ (សីលធម៌) របស់មនុស្សសុទ្ធតែត្រូវបានកំណត់ដោយមជ្ឈដ្ឋានជុំវិញ។ ទស្សនៈនេះក៏បានទាត់ចោលទាំងស្រុងនូវទំនាក់ទំនងរវាងសភាពចិត្ត និងចរិតលក្ខណៈនៃរូបរាងកាយរបស់មនុស្ស។ ទស្សនៈនេះអះអាងថា ឥទ្ធិពលរបស់សាលារៀនគ្មានប្រសិទ្ធភាពទេ ប្រសិនបើក្មេងនោះរស់នៅក្នុងមជ្ឈដ្ឋានគ្រួសារមិនល្អ។ អំណះអំណាងនេះចង្អុលបង្ហាញពីភាពចាំបាច់ដែលត្រូវឱ្យក្មេងរស់នៅក្នុងលក្ខខណ្ឌជីវិតធម្មតា។ ការអប់រំគ្មានឥទ្ធិពលអ្វីទាំងអស់ទៅលើមជ្ឈដ្ឋានជុំវិញ។ តាមទស្សនៈនេះ គឺមជ្ឈដ្ឋានជុំវិញទេដែលជាកត្តាកំណត់ទាំងស្រុង ការបណ្តុះបណ្តាលចិត្តរបស់មនុស្ស។

ទ្រឹស្តីទាំងពីរនេះគ្មានមូលដ្ឋានវិទ្យាសាស្ត្រទេ គឺជានយោបាយអប់រំដែលគ្មានលក្ខណៈវិទ្យាសាស្ត្រ ហើយមានបំណងបន្ទច់បង្អាក់ការសិក្សាបន្តទៅថ្នាក់លើរបស់កូនចៅគ្រួសារក្រីក្រ ជួបការលំបាក។

តាមការពិតជីវិតរបស់មនុស្សម្នាក់ៗមិនអាចកាត់ផ្តាច់ចេញពីមជ្ឈដ្ឋានសង្គមបានទេ។ ដូចនេះ តើមជ្ឈដ្ឋានជុំវិញ និងការបណ្តុះបណ្តាលចិត្តមនុស្ស និងសង្គមមានទំនាក់ទំនងរវាងគ្នា និងគ្នាឬទេ? នេះជាបញ្ហាស្មុគស្មាញដែលសរីរវិទូ ចិត្តវិទូ ទស្សនវិទូ បានយកចិត្តទុកដាក់បំផុត។

តាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របានឱ្យដឹងថា តាំងពីមួយរយពាន់ឆ្នាំមុនរហូតដល់សព្វថ្ងៃពេលដែលមនុស្សចេះគិតពិចារណា មនុស្សបានរស់នៅតាមច្បាប់ដែលសង្គមមនុស្សបានកំណត់ ដោយផ្អែកលើសកម្មភាពពលកម្ម ភាសា និងទំនាក់ទំនងក្នុងសង្គម។ លំនាំរីកចម្រើននៃសង្គមមនុស្សក៏ត្រូវបានប្រព្រឹត្តទៅតាមសង្គមប្រវត្តិដែរ។ ពីជំនាន់មួយទៅជំនាន់មួយ បុគ្គលម្នាក់ៗទទួលមរតកចរិតលក្ខណៈពូជសាសន៍តាមរបៀបពីរយ៉ាង៖

- តាមរយៈតំណពូជ : គេទទួលការប្រែប្រួលលក្ខណៈទម្រង់មុខមាត់ និងផ្នែកកាយវិការ...។
- តាមរយៈសង្គមប្រវត្តិ : គេទទួលការប្រែប្រួលផ្នែកសកម្មភាពប្រព័ន្ធប្រសាទ ជាពិសេសការប្រែប្រួលបាតុភូតចិត្តកម្រិត

ខ្ពស់ «ការគិត សញ្ចេតនា ឆន្ទៈ...»។

គ-ម្យ៉ាងទៀតជីវិតបញ្ញាដែលមនុស្សម្នាក់ៗបានទទួលពីជំនាន់មួយទៅជំនាន់មួយទៀត គឺសុទ្ធតែស្ថិតក្រៅខ្លួនគេទាំងអស់។

មរតកនៃចំណេះដឹងរបស់មនុស្សផ្នែកសម្ភារ និងស្មារតី ត្រូវបានកត់ត្រាទុកនៅលើផលិតផលសម្ភារ និងស្មារតីដូចជាឧបករណ៍ផលិតកម្ម ស្ថាបត្យកម្ម ស្នាដៃសិល្បៈ សម្លៀកបំពាក់ ម្ហូបអាហារ...។ ផលិតផលទាំងនេះ ក៏បង្ហាញផងដែរពីប្រវត្តិនៃការរីកចម្រើននៃសមត្ថភាពផ្លូវកាយ និងបញ្ញា ពីជំនាន់មួយទៅជំនាន់មួយរបស់មនុស្សជាតិ។

ដើម្បីរស់នៅ និងអភិវឌ្ឍ មនុស្សត្រូវទាក់ទង និងប្តូរបទពិសោធពីជំនាន់មួយទៅជំនាន់មួយ។ ហេតុនេះ គេត្រូវបង្រៀនមនុស្សជំនាន់ក្រោយអំពីវិទ្យាសាស្ត្រ ទំនាក់ទំនងសង្គម ការងារពលកម្ម និងល្បែង...។

ចំពោះយុវវ័យជំនាន់ថ្មី គេត្រូវប្រើបទពិសោធដែលបានទទួលនៅក្នុងលក្ខខណ្ឌថ្មីៗ ហើយបង្កើតបទពិសោធថ្មីៗថែមទៀតដើម្បីបង្កើតមរតកចំណេះដឹងដល់មនុស្សជាតិ។

ឃ-ការទទួលមរតកចំណេះដឹងមនុស្សជាតិ គឺយកចំណេះដឹង បញ្ញត្តិ ច្បាប់វិទ្យាសាស្ត្រទាំងឡាយទៅសិក្សា។ លំនាំនៃការសិក្សា ប្រព្រឹត្តទៅតាមដំណាក់ៗដូចតទៅនេះ សិក្សាទ្រឹស្តី ប្រតិបត្តិកែទម្រង់ឱ្យសមស្រប ដកស្រង់បទពិសោធ កសាង និងបង្កើតថ្មី។

ឧទាហរណ៍ៈ រៀនវិធីសាស្ត្របង្រៀន «ទ្រឹស្តី» រួចយកទៅអនុវត្តក្នុងថ្នាក់ កែលំអគុណភាព ដកស្រង់បទពិសោធន៍រកចំណុចខ្លាំង ចំណុចខ្សោយ បន្ទាប់មកទៀតបង្កើតវិធីថ្មី ដោយច្នៃប្រឌិតដើម្បីឱ្យមានលក្ខណៈច្បាស់លាស់ និងជាក់ស្តែង។

គ្រប់បាតុភូតចិត្តរបស់មនុស្ស ត្រូវបានបណ្តុះបណ្តាលតាមរយៈសកម្មភាពរបស់មនុស្សនោះ។ គ្រប់លំនាំនៃការបណ្តុះបណ្តាលសមត្ថភាពរបស់មនុស្ស គឺសុទ្ធតែជាកម្មវត្ថុនៃការអប់រំ។

តួនាទី និងភារកិច្ចរបស់សាលារៀន គឺរៀបចំគ្រប់សកម្មភាពដោយធ្វើយ៉ាងណាឱ្យទម្រង់នៃសកម្មភាពបង្រៀន រៀនអាចផ្តល់ឱកាសគ្រប់គ្រាន់ដល់គ្រូ និងសិស្សបណ្តុះសមត្ថភាពខ្លួនឯង។

(នៅមានត)

**ដកស្រង់ពីនាយកដ្ឋានបណ្ដុះបណ្ដាល និងនិក្រឹតការ**

៚۞៚

## ច្បាប់ល្បើកថ្មី

រៀនត្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កត់
ចង់ឈ្នះមនុស្សខឹង ឱ្យប្រឹងទប់អត់ វាដេរវាហត់
វាស្បថលែងខឹង។

ចង់ឈ្នះអសុរស ស្តីលេងឡេះឡោះ កុំធ្វើជាដឹង
យើងស្តីត្រង់ណា ឱ្យចំត្រង់ណឹង ឃើញរូបយើងរឹង
ខ្លាចយើងខាងក្រោយ។

បណ្ដាំក្រមង៉ុយ

# ការបាក់កម្លាំងប្រសាទនៃកូនយើង តើយើងត្រូវការពារយ៉ាងណា?

ដើម្បីជៀសវាងកុំឱ្យកូនយើងបាក់កម្លាំងប្រសាទ គប្បីយើងជ្រាបច្បាស់នូវបញ្ញត្តិ ៤ ប្រការ តែក្នុងនេះខ្ញុំសូមលើកយកបញ្ញត្តិទី១ មកជម្រាបជូនដូចតទៅនេះ៖

**បញ្ញត្តិទី១** : ព្រលឹងអាស្រ័យនឹងកាយ កាយអាស្រ័យនឹងព្រលឹង និងរបះដូងមួយមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ។ កាលកូនយើងនៅតូចប្រាជ្ញាវាតិចលុះកាយវាធំឡើងប្រាជ្ញាស្មារតីវាក៏លូតលាស់បានរឹងប៉ឹងជាលំដាប់តាមកាយដែរ។ មនុស្សធំកាលណាបើឈឺមានកម្លាំងខ្សោយជាមួយនោះ កម្លាំងគំនិតប្រាជ្ញាមនុស្សឈឺនេះក៏ចុះអន់ថយតាមកម្លាំងកាយដែរ។ សោតឯមនុស្សស្រវឹងស្រាវិញក៏ដូចគ្នា ព្រលឹងគំនិតប្រាជ្ញាមនុស្សនេះតែងតែវង្វេងវៃវល់ទៅតាមកាយដែលចុះទន់ល្វើយល្វើមួយពេល មួយកាលដោយចំហាយសុរាដែរ។

ឧទាហរណ៍ខាងលើនេះ ល្មមបញ្ជាក់បានថា ព្រលឹងពឹងពាក់នឹងកាយ។ អាស្រ័យហេតុនេះ ដើម្បីឱ្យប្រព័ន្ធសរសៃប្រសាទ ហើយនិងគំនិតប្រាជ្ញាស្មារតីបានមាំមួន យើងត្រូវលៃយ៉ាងណាឱ្យកាយកូនយើងបានមាំមួនដែរ។

តើយើងត្រូវបង្ហាត់កាយកូនយើងឱ្យទៅជាអ្នកកីឡាឬ? បើតាមគំនិតខ្ញុំថា មិនបាច់ហ្វឹកហ្វឺនកាយកូនយើងឱ្យដល់ថ្នាក់ជាអ្នកកីឡាទេ ព្រោះថាសាច់ដុំនៃកុមាររមែងផុះដាលមាំមួនបានដោយគ្រាន់តែធ្វើចលនាតាមធម្មតា។ តែក្នុងរឿងនេះ យើងជាមាតាបិតា និងជាអ្នកអប់រំទាំងឡាយ ល្មមចេះលៃលកយ៉ាងណាឱ្យកាយ និងព្រលឹងកូនយើងមានតុល្យភាព និងបានប្រកបដោយសុខដុមផង។

តាមមតិខាងលើនេះ អ្នកអានអាចអះអាងផ្ទុយនឹងខ្ញុំវិញបាន ព្រោះថាមានសិស្សស្គម ស្លេកស្លាំងរៀនពូកែ។ ជនជាតិបារាំងម្នាក់នាម ប៉ាស្កាល់ (PASCAL) ដែលមានកាយទុព្វលអាចទៅជាអ្នកប្រាជ្ញយ៉ាងឆ្នើមបាន។

ត្រង់ខទី១នេះ ខ្ញុំសូមឆ្លើយថាកុមារខ្លះស្គម តែកម្លាំងកាយ និងព្រលឹងវាមានតុល្យភាព ប៉ុន្តែចំពោះលោកប៉ាស្កាល់វិញ ខ្ញុំយល់ថាលោកជាមនុស្សពិសេស ហើយសូមជ្រាបថែមទៀតថា កូនយើងមិនមែនសុទ្ធតែប៉ាស្កាល់ទេ។

អាស្រ័យហេតុនេះ យើងមិនត្រូវបណ្តោយឱ្យកាយកូនយើងខ្សោយឡើយ បើយើងមានមធ្យោបាយល្មមធ្វើឱ្យវាមានកម្លាំងរឹងប៉ឹងឡើងវិញកើត។ បណ្ឌិត «ម៉ុងតែញ» ជាអ្នកមានអង្គកាយខ្សោយ តែមានអង្គព្រលឹងខ្លាំង។ គាត់តែងតាននឹងឈឺចាប់ក្នុងចិត្តជាប់ជានិច្ច។ មានម្តងគាត់មានប្រសាសន៍ថា: ចំណែកខ្លួនខ្ញុំ ខ្ញុំមិនត្រូវការអ្វីមកអប់រំព្រលឹងខ្ញុំទៀតឡើយ ខ្ញុំត្រូវការអប់រំតែកាយខ្ញុំឱ្យបានរឹងប៉ឹងឡើងវិញ ទើបខ្ញុំបំពេញមុខការខ្ញុំបានលទ្ធផលល្អ។ ខ្ញុំដឹងហើយថា កាយខ្សោយមិនបណ្តោយឱ្យព្រលឹង ឱ្យគំនិតប្រាជ្ញា ស្មារតីធ្វើការបានសម្រេចផលច្រើន ព្រោះព្រលឹងមាំមួនដែលពំនាក់អាស្រ័យទៅនឹងកាយទុព្វលត្រូវប្រឹងប្រែងធ្វើការតែឯងទ្វេមួយជាពីរ រួចបើធ្វើបែបនេះយូរៗទៅមុខជាបណ្តាលឱ្យមានការបាក់កម្លាំងមិនខាន។ ផ្ទុយទៅវិញ ប្រសិនបើព្រលឹងខ្សោយឋិតនៅក្នុងកាយមាំមួនវិញនោះ ខ្ញុំមិនដឹងជាយ៉ាងណាទៅវិញទេ។

នៅទីក្រុងធំៗ យើងមិនងាយនឹងចិញ្ចឹមកុមារឱ្យកាយវាមាំមួនតាមយើងត្រូវការឡើយ ដោយនៅទីនោះខ្វះខ្យល់អាកាស ខ្វះកន្លែងធ្វើចលនា ខ្វះការសម្រាកជាការចាំបាច់។ ខ្លួនកុមារដែលខ្វះអាហារធម្មជាតិខាងលើសម្រាប់ទ្រទ្រង់ជីវិតវាតែងតែនៅស្គមស្លេកមិនបានធំមាំ។ ភាពស្លេកនេះនាំឱ្យកាយាយតនៈវាធាប់រំភើបញាប់ញ័រ ជាហេតុបណ្តាលឱ្យមានការសៅហ្មងដល់ដំណើរឈាមរត់។

ឈាមរត់មិនបានស្រួល កាយមិនបានរឹងប៉ឹង ប្រាជ្ញាស្មារតីធាប់រំភើបញាប់ញ័រ បើយើងបណ្តែតបណ្តោយឱ្យកូនយើងរស់នៅបែបនេះយូរទៅ ដល់វាធំពេញចំណាស់ឡើង កូនយើងពុំបានជាមនុស្សខ្លាំងពូកែទាំងកាយទាំងព្រលឹងឡើយ។

លោក **ខៃម ឆាន**




# អភិវឌ្ឍចំណេះដឹង និងបំណិន

គ្រប់នាយកសាលាទាំងអស់តែងត្រូវបានដំឡើងឋានៈពីគ្រូបង្រៀនប្រចាំថ្នាក់ ហើយពួកគាត់ភាគច្រើនយល់ថា ធ្វើជានាយកសាលាមិនមែនជាការលំបាកអ្វីទេ។ ពួកគាត់គិតថា ការងារនេះទាមទារត្រឹមអនុវត្តតាមនូវអ្វីដែលថ្នាក់លើបញ្ជាមក និងអនុវត្តការងារប្រចាំថ្ងៃតាមទម្លាប់ឱ្យបានល្អទៅនោះវាគ្រប់គ្រាន់ណាស់ទៅហើយ។ ប៉ុន្តែតាមការពិត ការងារជានាយកសាលាមិនមែនងាយស្រួលទេ!! ដឹកនាំពិបាក ហើយដឹកនាំសាលារៀនមួយកាន់តែពិបាកថែមទៀត។ ភារកិច្ចរបស់នាយកសាលាជាភារកិច្ចលំបាកស្មុគស្មាញ។ នាយកសាលាធ្វើការជាមួយក្រសួងអប់រំផងជាមួយសហគមន៍ផង ជាមួយមាតាបិតាសិស្សផង ជាមួយគ្រូបង្រៀនផង ជាមួយសិស្សផង... ហើយដោះស្រាយគ្រប់ការងារទាំងអស់ក្នុងសាលាថែមទៀតផង។ ខ្ញុំចងចាំនូវសំដីរបស់នាយកសាលាម្នាក់ដែលបាននិយាយមកកាន់ខ្ញុំថា «ក្នុងសាលារបស់ខ្ញុំមិនមែនតែគ្រូទេដែលបង្រៀនសិស្ស សូម្បីតែដងទង់ជាតិ សួនច្បារ ដើមឈើ អ្នកលក់នំ... ក៏បង្រៀនសិស្សដែរ។ ខ្ញុំបានខិតខំធ្វើឱ្យរបស់ទាំងនោះក្លាយជាគ្រូបង្រៀនដ៏ល្អ តែខ្ញុំមានការលំបាកនឹងសម្រេចបាន ព្រោះខ្ញុំពុំមានចំណេះដឹង និងបំណិនគ្រប់គ្រាន់»។ ដូចនេះ ដើម្បីក្លាយជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព នាយកសាលាត្រូវការជាសារវន្តនូវចំណេះដឹង និងបំណិនគ្រប់គ្រាន់។ ក្នុងជំពូកទី៤ យើងបានណែនាំនាយកសាលាឱ្យបង្កើនស្វ័យឱ្យតម្លៃ និងមានការឱ្យតម្លៃបែបវិជ្ជមាន។ ប៉ុន្តែការស្វ័យឱ្យតម្លៃ និងតម្លៃវិជ្ជមានតែឯងមិនគ្រប់គ្រាន់សម្រាប់ឱ្យក្លាយជាអ្នកដឹកនាំខ្លាំងពូកែបានទេ។ វាទាមទារថែមទៀតនូវចំណេះដឹង និងបំណិន។

**១-ចំណេះដឹង**

ដូចបាននិយាយខាងលើហើយថា ការកិច្ចដឹកនាំសាលារៀនជាភារកិច្ចមួយពិបាកស្មុគស្មាញ។ ដូចនេះ នាយកសាលាចាំបាច់ត្រូវមានចំណេះដឹងទូលំទូលាយ។ ឧទាហរណ៍ សព្វថ្ងៃនេះមាននាយកសាលាមួយចំនួនត្អូញត្អែរថា គាត់មានការលំបាកក្នុងការបង្កើតនូវចក្ខុវិស័យសម្រាប់សាលារបស់គាត់ និងពិបាកក្នុងការកសាងនូវផែនការដើម្បីធ្វើការឱ្យសម្រេចនូវចក្ខុវិស័យនោះ។ ទាំងនេះក៏ព្រោះតែចំណេះដឹងទូទៅរបស់គាត់ ពិសេសចំណេះដឹងអំពីប្រទេសរបស់គាត់ អំពីការអភិវឌ្ឍប្រទេសជាតិរបស់គាត់មិនបានទូលំទូលាយ។ ចក្ខុវិស័យរបស់សាលាត្រូវផ្សារភ្ជាប់ទៅនឹងតំបន់ដែលសាលាស្ថិតនៅ ប្រទេសជាតិ ការអភិវឌ្ឍប្រទេស ចក្ខុវិស័យរបស់ក្រសួង និងស្ថានភាពក្នុងសកលលោកផងដែរ។ វាត្រូវតែជាការរួមបញ្ចូលគ្នានៃកត្តាទាំងអស់នេះ។ ដូចនេះនាយកសាលាត្រូវមានចំណេះដឹងទូលំទូលាយអំពីប្រទេសរបស់ខ្លួន និយាយដោយឡែក និងអំពីសកលលោកនិយាយរួម។

ក្រៅពីចំណេះដឹងទូទៅទូលំទូលាយដូចពោលខាងលើ ដោយហេតុថា នាយកសាលាមានការទទួលខុសត្រូវ

ក្នុងការផ្តល់ការអប់រំល្អជូនកុមារនោះ នាយកសាលាទាមទារឱ្យមានចំណេះដឹងគ្រប់គ្រាន់ខាងវិជ្ជាជីវៈថែមទៀត។ ក្នុងឧទាហរណ៍ខាងលើដើម្បីមានលទ្ធភាពអាចបង្កើតបាននូវចក្ខុវិស័យ និងផែនការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់សាលារៀននាយកសាលាត្រូវការផងដែរនូវចំណេះដឹង និងបំណិនវិជ្ជាជីវៈដែលអាចឱ្យបង្កើតចក្ខុវិស័យនោះបាន អាចធ្វើការជាមួយសហគមន៍ និងអាចចលនាគេឱ្យចូលរួមក្នុងការងារនេះបាន។ល។ ម្យ៉ាងទៀត ដូចយើងបាននិយាយខាងដើមរួចមកហើយ នាយកសាលាត្រូវវាយតម្លៃសិស្សទាំងអស់ប្រកបដោយសមធម៌ ត្រូវមានការជឿជាក់ថា កុមារទាំងអស់អាចរៀនបាន។ ពួកគេអាចប្រកាន់ឥរិយាបថបែបនេះ និងមានការជឿជាក់បែបនេះបានលុះត្រាតែគេមានចំណេះដឹងជ្រៅជ្រះខាងចិត្តវិទ្យា ពិសេសចិត្តវិទ្យាកុមារ ការវិវត្តខាងរាងកាយ និងសញ្ចេតនារបស់កុមារ ការរីកលូតលាស់នៃខួរក្បាលរបស់កុមារ វិធីរៀនប្លែកៗរបស់កុមារ។ល។ មានចំណេះដឹង និងបំណិនទាំងនេះនាយកសាលាអាចឱ្យក្លាយខ្លួនជាធនធានរស់សម្រាប់គ្រូបង្រៀនក្នុងសាលា។ គាត់អាចជួយពួកគេឱ្យមានការរីកចម្រើនលើការយល់ដឹងអំពីកុមារដែលប្រការនេះអាចជួយពួកគេអាចប្រែប្រួលការប្រព្រឹត្តរបស់គេចំពោះកុមារម្នាក់ៗបានកាន់តែសមស្រប។

ភារកិច្ចសំខាន់របស់នាយកសាលា គឺជួយគ្រូបង្រៀនឱ្យពួកគេកែលម្អសមត្ថភាពបង្រៀនរបស់គេ។ ភារកិច្ចនេះទាមទារឱ្យគាត់ចំណាយពេលនិយាយជាមួយគ្រូបង្រៀនពីយុទ្ធសាស្ត្របង្រៀន និងរៀន សង្កេតការបង្រៀនរបស់គ្រូ ផ្តល់ជូនគ្រូបង្រៀននូវព័ត៌មានត្រឡប់ដែលអាចជួយពួកគេបាន និងជួយពួកគេនូវគំនិតថ្មីៗដែលមានប្រយោជន៍។ ប៉ុន្តែសព្វថ្ងៃនេះមិនមាននាយកសាលាច្រើនទេដែលបានបំពេញនូវភារកិច្ចដ៏មានប្រយោជន៍នេះ ហើយនាយកសាលាខ្លះមានការលំបាកយ៉ាងច្រើនទាំងក្នុងការផ្តល់ព័ត៌មានត្រឡប់ក៏ដូចជាការណែនាំ។ ប្រការនេះក៏ដោយសារតែគាត់មិនមានការយល់ទូលំទូលាយអំពីវិធីប្លែកៗនៃការបង្រៀន និងពីមុខវិជ្ជានានាដែលត្រូវបង្រៀន។ ដោយនាយកសាលាមានភារកិច្ចសំខាន់ក្នុងការជួយទ្រទ្រង់គ្រូបង្រៀនក្នុងដំណើរការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គេនោះ គាត់ត្រូវមានចំណេះដឹងទូលំទូលាយលើវិស័យអប់រំ និងមុខវិជ្ជាផ្សេងៗដែលត្រូវបង្រៀន។ គាត់ត្រូវយល់ឱ្យបានជ្រៅជ្រះលើវិធីសាស្ត្របង្រៀន គោលវិធីសិស្សមជ្ឈមណ្ឌល ជាតុផ្សេងៗ នៃសាលាកុមារមេត្រី ការអប់រំបញ្ចូលគ្នា។ល។ ចំណេះដឹង និងបំណិនទាំងនេះមិនអាចទទួលបានត្រឹមការចូលរួមក្នុងសិក្ខាសាលានោះទេ វាទាមទារឱ្យនាយកសាលាម្នាក់ៗអានឱ្យបានច្រើន ជជែកគ្នាឱ្យបានច្រើន និយាយរួមគឺរៀនរាល់ថ្ងៃ គឺជាអ្នករៀនជាប្រចាំ។ នៅពេលដែលនាយកសាលាបង្ហាញខ្លួនជាអ្នកសប្បាយក្នុងការរៀននូវគំនិតថ្មីៗហើយនោះ មន្ត្រីរបស់គាត់ក៏មានអារម្មណ៍ជាសុកក្នុងការបង្កើតនូវគំនិតថ្មីៗដើម្បីធ្វើឱ្យសាលារៀនមានការប្រែប្រួលដែរ។

នាយកសាលាក៏ត្រូវមានការជឿជាក់ផងដែរថា ដើម្បីបានក្លាយជាអ្នកដឹកនាំពូកែនោះ គាត់ត្រូវដឹកនាំគ្រប់វិស័យទាំងអស់ក្នុងសាលាឱ្យបានប្រកបដោយជោគជ័យ។ ប្រការនេះ ទទឹមនឹងត្រូវមានចំណេះដឹងទូលំទូលាយ គាត់ត្រូវក្តាប់បាននូវរាល់ចំណេះដឹងថ្មីៗ។ ដូចនេះគាត់ត្រូវតែរៀនថែមទៀតជារៀងរាល់ថ្ងៃ។ ការសិក្សាជាប្រចាំបែបនេះនឹងជួយគាត់ឱ្យស្ថិតនៅជានិច្ចក្នុងបច្ចុប្បន្នកាល ហើយអាចឈានទៅរកអនាគតកាល។ ប្រសិនបើមិនរៀនទេ គាត់នឹងធ្លាក់ទៅក្នុងអតីតកាល ហើយគ្មានពេលនឹងបានក្លាយជាអ្នកដឹកនាំដែលមានជោគជ័យទេ។

វិធីមួយនៃការពង្រីកចំណេះដឹង គឺការអាន។ នាយកសាលាត្រូវតែជាអ្នកអានជាប្រចាំ និងជាអ្នកស្រេកឃ្លានក្នុងការអាន។ ដោយសៀវភៅដែលមានព័ត៌មានដែលមានប្រយោជន៍សម្រាប់យើងច្រើនតែជាភាសាបរទេសនោះ នាយកសាលាត្រូវតែមានសមត្ថភាពអាចប្រើប្រាស់បានយ៉ាងតិចពីរភាសា គឺភាសាជាតិមួយ និងមួយទៀតភាសាបារាំង ឬអង់គ្លេស។

ម្យ៉ាងទៀត នៅចំពោះមុខការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ព័ត៌មានថ្មីៗត្រូវបានកើតឡើងរៀងរាល់ថ្ងៃ។ ទិន្នន័យព័ត៌មានយ៉ាងសម្បូរបែបត្រូវបានផ្សព្វផ្សាយជារៀងរាល់ថ្ងៃតាមប្រព័ន្ធព័ត៌មានវិទ្យា។ ដើម្បីអាចចាប់យកនូវព័ត៌មានទាំងនេះនាយកសាលាត្រូវតែមានចំណេះដឹងបន្ថែមទៀតពីបច្ចេកវិទ្យា។

(នៅមានត)

លោក ពីរ សាមិត

## វេយ្យាករណ៍

# របៀបប្រើពាក្យ

### រមែង រមែងតែ រែង រែងតែ តែង តែងតែ

ពាក្យទាំងអស់នេះ ជាកិរិយានុគ្រោះ ឬជាកិរិយាស័ព្ទជំនួយសម្រាប់រៀងពីខាងដើមកិរិយាស័ព្ទទាំងឡាយ មានន័យថាប្រហែលៗគ្នា។

ឧ.សិស្សល្អ រមែងមកដល់សាលារៀនទាន់ពេល។

- អ្នកលក់រមែងចង់បានចំណេញ រីឯអ្នកទិញរមែងចង់បានច្រើន ហើយថោកផង។
- ឆោតល្ងង់រមែងជឿដោយឥតពិចារណា។
- អ្នកឈឺរមែងតែឆោត ព្រោះគេចង់រស់។
- អ្នកខ្លាំរែង ស្លាប់ប្រាជ្ញ ឯអ្នកខ្លាចរែងធ្វើទាហាន។
- ក្ររែងធ្វើជាមាន អ្នកឥតសន្ដានរែងមើលងាយគេ (សុភាសិតបុរាណ)។

### ត្រូវការ ប្រាថ្នា ចង់

ពាក្យទាំងបីនេះមានន័យប្រហាក់ប្រហែលគ្នា តែមិនដូចគ្នាទេ។ អ្នកខ្លះវេលាប្រើច្រើនប្រើរួមគ្នាទាំងបីក៏មានហាក់ដូចជាពាក្យទាំងបីនេះជាវេវចនៈនឹងគ្នា តែតាមពិតពាក្យទាំងបីនេះមានន័យផ្សេងគ្នាដូច្នេះ :

- ត្រូវការ មានន័យថា ត្រូវកមនុស្ស ឬសត្វ ឬក៏របស់អ្វីមួយ ដើម្បីយកមកបំពេញការខ្វះខាតដែលខានមិនបាន។

ឧ.គេត្រូវការមនុស្សម្នាក់ដែលចេះភាសាខ្មែរជ្រៅជ្រះដើម្បីនិយាយព័ត៌មានតាមវិទ្យុជាតិ។

- មនុស្សទាំងអស់ត្រូវការសំពត់អាវ ដើម្បីស្លៀកពាក់។ ប្រាថ្នា ហើយនឹងចង់ មានន័យដូចគ្នា ជួនកាលគេប្រើ ប្រាថ្នា ជួនកាលគេប្រើ ចង់។ គ្រាន់តែពាក្យប្រាថ្នា ជាពាក្យមិនសូវប្រើក្នុងការនិយាយទូទៅប៉ុណ្ណោះ។

ឧ.ក្ដីប្រាថ្នារបស់មនុស្សធំណាស់។ មនុស្សមានសេចក្ដីប្រាថ្នាឥតមានទីបំផុត។ គេបាន របស់ នេះហើយគេប្រាថ្នារបស់នោះទៀត។

ឧ.គេចង់ទិញ ឡានមួយដើម្បីជិះកម្សាន្ត។ ប៉ុន្តែគេមិនត្រូវការទិញទេ (គេមិនមែនខានទិញមិនបានទេ) បើគេត្រូវការប្រាក់នោះ សម្រាប់ជីវភាពគ្រួសារសិន។

### គួរ គួរតែ គប្បី គប្បីតែ ត្រូវ ត្រូវតែ

ពាក្យទាំងនេះបម្រើជាកិរិយានុគ្រោះ ឬជាកិរិយាស័ព្ទជំនួស មានន័យផ្សេងគ្នាដូច្នេះ :

១-គួរ ជាពាក្យបញ្ជាក់នូវការណែនាំ ឬការបបួល ឥតមានបង្ខំអ្វីឡើយ។

ឧ.យើងគួរខំរៀនភាសាខ្មែរ។ យើងមិនគួរនិយាយពាក្យ ទ្រគោះ ចំពោះអ្នកដទៃទេ។

២-គួរតែ ជាពាក្យបញ្ជាក់នូវការណែនាំ ឬការបបួលស្ទើរតែបង្ខំ។

ឧ.លោកគួរតែចាំខ្ញុំ មិនគួរទៅចោលខ្ញុំសោះ។

៣-គប្បី គប្បីតែ ជាពាក្យបញ្ជាក់នូវការណែនាំ និងការបបួល ដូច គួរ និងគួរតែផង បញ្ជាក់នូវការចាំបាច់ផង។ ហើយច្រើនតែប្រើក្នុងការសរសេរជាងការនិយាយ។

ឧ.មុននឹងធ្វើទាន គេគប្បីពិចារណាថា តើគប្បីធ្វើទានបែបណា ដើម្បីឱ្យបានប្រយោជន៍ដល់ជនច្រើនគ្នា។ គេគប្បីតែហាមប្រាមកូនចៅ កុំឱ្យវាទៅបន្ទោរបង់លាមកនៅតាមផ្លូវ អ្នកផងធ្វើដំណើរទៅ គេខ្ពើម ឆ្អើម។

៤-ត្រូវ ត្រូវតែ ជាពាក្យបញ្ជាក់នូវការចាំបាច់ ការបង្ខំ ការត្រូវធ្វើខានមិនបាន។ ជួនកាលគេប្រើពាក្យថាចាំបាច់ និងមិនចាំបាច់ក្នុងប្រយោគបដិសេធ។

ឧ.យើងត្រូវប្រតិបត្តិច្បាប់ចរាចរ។ យើងមិនត្រូវប្រព្រឹត្តបំពានច្បាប់ឡើយ។ អំពើអាក្រក់យើងត្រូវតែចៀសវាង អំពើល្អយើងត្រូវតែធ្វើ។

## សុទ្ធតែ សុទ្ធសឹងតែ

១-សុទ្ធតែ មានន័យថា ទាំងអស់ប្រើរៀងខាងដើមកិរិយាស័ព្ទ។

ឧ.មនុស្ស និងសត្វ សុទ្ធតែរស់នៅដោយសារអាហារ។

ជួនកាលគេប្រើក្នុងប្រយោគដែលមានពាក្យថា ទាំងអស់នៅក្នុងនោះផង។

ឧ.មនុស្សទាំងអស់ សុទ្ធតែចង់បានសេចក្ដីសុខ និងសេចក្ដីចំរើន។

២-សុទ្ធសឹងតែ មានន័យថា ស្ទើរតែទាំងអស់ ជិតតែទាំងអស់ គឺមិនទាំងអស់ទេ ប្រើរៀងខាងដើមកិរិយាស័ព្ទដូចគ្នា។

ឧ.សៀវភៅនៅក្នុងបណ្ណាល័យនោះ សុទ្ធសឹងតែជាសៀវភៅចាស់ៗ។

## ជិតតែ សឹងតែ ស្ទើរតែ

ពាក្យទាំង៣នេះមានន័យដូចគ្នា ប្រើផ្លាស់ប្ដូរគ្នាបាន ច្រើនប្រើរៀងខាងដើមពាក្យថា ទាំងអស់ រាល់ គ្រប់។

ឧ.មនុស្សស្ទើរតែទាំងអស់សប្បាយរីករាយ។

- សៀវភៅជិតតែទាំងអស់ ជារបស់ខ្ញុំ។

- ខ្ញុំឃើញគាត់នៅត្រង់ទីនោះសឹងតែរាល់ថ្ងៃ។

លោក **ខែម ផាន**

«ទឹកអាចឱ្យទូកអណ្ដែតទៅមុខ
ជិះយានចានសុខស្រណុកកាយា
តែទូកអាចលិចចុះក្នុងជលសា
ផ្ដាច់បង់សង្ខារដោយសារទឹកដែរ»។

ប៊ុត សាវង្ស

# សាលារៀនជាមជ្ឈដ្ឋានផ្សាយនូវវិជ្ជាទូទៅ

នៅពេលនេះខ្ញុំបាទនឹងអធិប្បាយអំពី សាលារៀនជាមជ្ឈដ្ឋានផ្សាយនូវវិជ្ជាទូទៅ បានសេចក្ដីជាភាសាបារាំងថា "L'ECOLE EST UN CENTRE DE RAYONNEMENT"។

ក៏ប៉ុន្ដែមុននឹងចូលក្នុងប្រធានបទនេះ ខ្ញុំបាទសូមនិយាយអំពីបេសកកម្មនៃសាលារៀនជាមុនសិន។ បញ្ហានេះជាបញ្ហាសាមញ្ញ ធម្មតាពិតមែនហើយ ប៉ុន្ដែជាបញ្ហាមួយមានសារៈសំខាន់។

សាលារៀនស្វែងរកវត្ថុបំណង ២ ជាមុនៈ

- ការប្រាជ្ញាប្រយោជន៍
- ការអប់រំ។

១- ការប្រាជ្ញាប្រយោជន៍:

ការបង្រៀនរបស់យើង គឺរៀបចំក្មេងឱ្យទៅកាន់ជីវភាពដោយផ្ដល់ឱ្យសិស្សនូវចំណេះវិជ្ជាសមប្រកបទៅនឹងសេចក្ដីត្រូវការរបស់សិស្សក្នុងអនាគតកាល។

២- ការអប់រំ :

ក្នុងផ្នែកនេះ យើងអប់រំសិស្សខាងផ្នែកបញ្ញា និងផ្នែកចរិយា សីលធម៌ ពោលគឺយើងបណ្ដុះបញ្ញាពង្រីកបញ្ញាធ្វើឱ្យសិស្សចេះគិត ចេះពិចារណា ស្គាល់ខុស ស្គាល់ត្រូវ។ បញ្ញាមានន័យថា «ធម្មជាតិដឹងដោយបការៈ ឬសេចក្ដីយល់ឃើញជាក់ច្បាស់»។

ប្រភពនៃការបណ្ដុះបញ្ញាមានបី[១]:

១-បញ្ញាអាចកើតឡើងបានដោយការព្យាយាមសិក្សារៀនសូត្រ ស្ដាប់ពីសំណាក់បណ្ឌិត សប្បុរស។ បញ្ញានោះឈ្មោះថា សុតមយបញ្ញា គឺបញ្ញាកើតពីការស្ដាប់ ការសិក្សារៀនសូត្រ។

បញ្ញាកើតឡើងបានដោយការខិតខំព្យាយាមសិក្សាក្បួនខ្នាត និងស្ដាប់ឱ្យយល់ពីទស្សនៈ និងគតិបណ្ឌិតរបស់គ្រូអាចារ្យ។

២-ការស្ដាប់បានហើយទុកដាក់ក្នុងចិត្តដោយត្រូវទំនង ត្រិះរិះ ពិចារណាសព្វគ្រប់ ក៏កើតមានបញ្ញាឡើង។ បញ្ញានេះឈ្មោះថា ចិន្ដមយបញ្ញា គឺបញ្ញាកើតពីការត្រិះរិះពិចារណារកហេតុផល។ បញ្ញាអាចញ៉ាំងបុគ្គលឱ្យយល់ត្រូវ គិតត្រូវ និងធ្វើត្រូវជាគតិប្រចាំជីវិត។

៣-បញ្ញាកើតពីការហ្វឹកហាត់ចិត្តឱ្យស្ថិតនៅក្នុងអារម្មណ៍តែមួយមិនឱ្យរវើរវាយ។បញ្ញានោះឈ្មោះថាគឺភាវនាមយបញ្ញា គឺបញ្ញាប្រៀបដូចពន្លឺ។

យើងអប់រំសិស្សឱ្យបានទៅជាមនុស្សដែលអាចរស់នៅបានស្រួលក្នុងតំបន់របស់ខ្លួន ក៏ដូចជាក្នុងសង្គមទូទៅ តែយើងត្រូវអប់រំឱ្យបានទៅជាមនុស្សចេះគិតវែងឆ្ងាយ ចេះយល់គំនិតអ្នកដទៃ ចេះពិចារណា ចេះឱ្យតម្លៃដោយឥតក័ន្ទប្រឡុំ។

គោលបំណងនៃការបង្រៀនសិស្ស គឺមិនមែនចង់បង្រៀនសិស្សឱ្យចេះសព្វគ្រប់ទាំងអស់ទេ។ ការសំខាន់ជាងគេ គឺការចង់ឱ្យសិស្សចេះពិតប្រាកដ ចេះច្បាស់លាស់អ្វីៗដែលសិស្សបានរៀន។ លុះសិស្សចាកចេញពីសាលារៀនកាលណា សិស្សនោះអាចស្វែងរកចំណេះវិជ្ជាបន្ដទៅទៀតដោយខ្លួនឯង ពីព្រោះមានទម្លាប់ចេះរៀនខ្លួនឯងស្រាប់។

---

១-សៀវភៅមាតិកាជីវិតនៃព្រះពោធិសត្វរបស់ឯកឧត្ដមបណ្ឌិត កុល ផេង ព.ស.២៥៥២

ចេះគឺចេះពិតប្រាកដ មានគំនិតប្រាជ្ញាទូលំទូលាយ នេះហើយគឺជាគោលដៅដែលសិស្សានុសិស្សប្រាថ្នានៅក្រោយពេលចប់ការសិក្សា។ ដូចនេះ ត្រូវ «បង្រៀនតិច តែបង្រៀនល្អ»។

គ្រូដែលបានជ្រើសរើសតំណែងជាអ្នកបង្រៀនសិស្ស ជាអ្នកចិញ្ចឹមសិស្ស ក៏អាចបានដឹងច្បាស់ថា ក្នុងវិស័យអប់រំនេះ គ្រូមិនអាចបំពេញមុខងារតែម្នាក់ឯងបានឡើយ។ យើងត្រូវដឹងថា តំបន់ដែលក្មេងរស់នៅនោះ ក៏មានឥទ្ធិពលទៅលើស្មារតី ចិត្តថ្លើមរបស់ក្មេងដែរ។ ការអប់រំរបស់លោកគ្រូម្នាក់ៗអាចមានប្រសិទ្ធភាពក្នុងការជាស់តឿនក្រើនរំឭកសតិអារម្មណ៍ និងកំណើននៃបុគ្គលិកលក្ខណៈរបស់សិស្សពិតមែនហើយ តែមានឥទ្ធិពលមួយទៀត មានកម្លាំងខ្លាំងក្លាណាស់ ហើយស្ថិតស្ថេរថែមទៀត អាចជំរុញអប់រំគំនិត និងចិត្តសិស្សបន្តិចម្ដងៗ គឺការអប់រំដែលចេញមកពីតំបន់ ឬមជ្ឈដ្ឋានដែលសិស្សរស់នៅ។

ដូច្នេះគ្រូត្រូវតែស្គាល់យ៉ាងច្បាស់លាស់ តំបន់ ឬមជ្ឈដ្ឋានដែលក្មេងរស់នៅ ដើម្បីជួយជ្រោមជ្រែងឱ្យតំបន់នោះ មជ្ឈដ្ឋាននោះមានការលូតលាស់ មានរស្មីភ្លឺចិញ្ចាចឡើង ព្រោះថាបុគ្គលិកលក្ខណៈរបស់ក្មេងរីកឡើង តែក្នុងលក្ខខណ្ឌដ៏ប្រពៃដូចជារុក្ខជាតិនឹងធំធាត់ឡើងតែនៅលើដីណាដែលមានជីជាតិគ្រប់គ្រាន់។

អ្នកអប់រំត្រូវតែយកចិត្តទុកដាក់ រៀបចំធ្វើតំបន់នេះ មជ្ឈដ្ឋាននោះឱ្យមានសុខុមតែឥទ្ធិពលល្អទៅលើក្មេង ពីព្រោះការអប់រំដែលយើងធ្វើទៅលើក្មេងគឺការអប់រំគ្រប់សព្វទាំងអស់ តែការអប់រំប្រភេទនេះត្រូវតែឋិតនៅក្នុងឯកភាព។

ឯកភាពនេះនឹងធ្វើទៅបានលុះណាតែមានសហប្រតិបត្តិការយ៉ាងស្មោះត្រង់រវាងកម្លាំងទាំងអស់ដែលអាចជួយអប់រំក្មេងបាន៖

- ទី១ គឺសហប្រតិបត្តិការរវាងគ្រូទាំងអស់ និងនាយកសាលារៀន
- ទី២ គឺសហប្រតិបត្តិការរវាងគ្រូ និងមនុស្សនៃសង្គមដែលក្មេងរស់នៅ
- ទី៣ គឺសហប្រតិបត្តិការយ៉ាងស្មោះត្រង់ យ៉ាងជិតស្និទ្ធ ដោយមិនប្រាថ្នាប្រយោជន៍ រវាងគ្រូនិងសិស្ស ពីព្រោះសិស្សជាអ្នកស្ថាបនាបុគ្គលិកលក្ខណៈ និងអនាគតរបស់ខ្លួន។

(នៅមានត)

**លោក ថែម ផាន**

៦៣៩

| | | |
|---|---|---|
| ក្រកិច្ចក្រកល | ក្រដឹងក្រយល់ | ក្រវៃឆ្លាស់ |
| ទាំងប្រាំនេះសុទ្ធ | តែក្រទាំងអស់ | ប្រាជ្ញាស្រួចស្រស់ |
| | ទើបក្រឃ្លាតបាន។ | |
| ខ្វះការអប់រំ | រមែងច្រឡំ | ខ្វះៗពុំខាន |
| បើលុះតែខំ | អប់រំឱ្យមាន | ការថ្លឹកទើបបាន |
| | រួចផុតបាកក្រ។ | |

**សម្ដេច ជួន ណាត**

# គណិតវិទ្យា

## ការស្រាវជ្រាវរកបម្រាប់មានប្រយោជន៍

**បំណងចំណេះ**

- អានព័ត៌មានផ្សេងៗ
- ញែកដាច់ពីគ្នានូវព័ត៌មានដែលមានប្រយោជន៍ និងឥតប្រយោជន៍
- ជ្រើសរើសព័ត៌មានដែលមានប្រយោជន៍។

### I- គោលបំណងរបស់សន្លឹកបត្រ

ដឹកនាំសិស្សឱ្យយល់ច្បាស់ថា ព័ត៌មានទាំងឡាយដែលមានក្នុងចំណោទមិនមែនសុទ្ធតែមានប្រយោជន៍ជានិច្ច ដើម្បីដោះស្រាយចំណោទនោះទេ។

ហ្វឹកហាត់សិស្សឱ្យចេះជ្រើសរើសព័ត៌មានជាក់លាក់ដែលទាក់ទងនឹងសំណួរ។

**<u>ចំណោទ</u>**

ពូសំណាងសម្រេចចិត្តរៀបឥដ្ឋការ៉ូនៅចង្ក្រានបាយ ១០ម² និងនៅបន្ទប់បាយ ១៥ម²។ គាត់ជ្រើសរើសយកឥដ្ឋការ៉ូរាងការេដែលមានជ្រុង២០សម។ គាត់ទិញ៩កែស ដែលក្នុងមួយកែសមាន១០០ការ៉ូ តម្លៃក្នុងមួយកែសៗ ៥០០០០៛។ តើពូសំណាងចំណាយប្រាក់អស់ប៉ុន្មាន?

### II- ការរៀបចំរបស់គ្រូ

គ្រូត្រូវចម្លងចំណោទដាក់ក្តារខៀនមុនម៉ោងបង្រៀន។

### III- លំនាំនៃការបង្រៀន

**<u>ដំណាក់ទី១</u>** : អំណាន និងការយល់អត្ថន័យនៃអត្ថបទ

- ឱ្យសិស្សអានចំណោទនៅលើក្តារខៀនដោយស្ងៀមស្ងាត់
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សអាន
- គ្រូសួរៈ «តើក្នុងចំណោទនេះគេនិយាយអំពីអ្វីខ្លះ?»
- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់
- គ្រូបន្តសំណួរ :

«តើគេអាចដោះស្រាយចំណោទនេះបានដែរឬទេ? ព្រោះអ្វី?»

«តើព័ត៌មានទាំងអស់នៅក្នុងចំណោទនេះសុទ្ធតែមានប្រយោជន៍ដែរឬទេ?»

- ចំពោះសំណួរនីមួយៗ គ្រូត្រូវឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់។
-ឱ្យសិស្សដទៃទៀតតាមដានផ្ទៀងផ្ទាត់ និងកែលំអ។

**<u>សំណូមពរ:</u>** ក្នុងចំណោទនេះ មានទាំងព័ត៌មានមានប្រយោជន៍ និងឥតប្រយោជន៍។ ដូច្នេះ ចូររកព័ត៌មានទាំងឡាយណាដែលឥតប្រយោជន៍ដោយកត់ត្រាព័ត៌មានទាំងនោះនៅលើក្រដាសព្រាង។

- ឱ្យសិស្សរកព័ត៌មានដែលមានប្រយោជន៍ជាបុគ្គល ឬជាដៃគូ ដោយកត់ត្រាក្នុងក្រដាសព្រាង។
- ឱ្យសិស្សរកព័ត៌មានដែលឥតប្រយោជន៍ជាបុគ្គល ឬជាដៃគូដោយកត់ត្រាក្នុងក្រដាសព្រាង។
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សស្រាវជ្រាវ។

- ដើរពិនិត្យមើលការងាររបស់សិស្ស។

**ការបូកសរុប**

- ឱ្យសិស្សម្នាក់ឡើងបង្ហាញនូវចម្លើយរបស់គេ ដោយរៀបរាប់ពន្យល់ផង។
- គ្រូកត់ត្រាជាបន្តបន្ទាប់នូវចម្លើយរបស់សិស្សលើក្តារខៀន។
- ឱ្យសិស្សដទៃទៀតផ្ទៀងផ្ទាត់ ផ្ទុយ ផ្តល់ចម្លើយរបស់គេ និងជួយកែលម្អ។
- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់។

*ប្រសិនបើមានចម្លើយផ្សេងៗគ្នា គ្រូត្រូវឱ្យសិស្សទាំងនោះឡើងមកបង្ហាញចម្លើយរបស់គេដល់សិស្សឯទៀត ដោយរៀបរាប់ពន្យល់ផង។

- អនុវត្តដូចលំនាំបង្រៀនខាងលើចំពោះចម្លើយផ្សេងៗទៀតរបស់សិស្ស។

**ជំណាក់ទី២** : ដោះស្រាយចំណោទ

- ឱ្យសិស្សដោះស្រាយចំណោទជាបុគ្គលលើក្រដាសព្រាង។
- ទុកពេលឱ្យសិស្សដោះស្រាយ (២ ឬ៣នាទី)។
- គ្រូដើរត្រួតពិនិត្យការងាររបស់សិស្ស។

**ជំណាក់ទី៣** : ការបូកសរុប

- ឱ្យសិស្សម្នាក់មកបង្ហាញចម្លើយរបស់គេ។
- ឱ្យសិស្សឯទៀតផ្ទៀងផ្ទាត់ និងផ្តល់ចម្លើយរបស់គេ ព្រមទាំងជួយកែលម្អ។
- ឱ្យសិស្សម្នាក់ឡើងមកក្តារខៀន គូសចោលនូវព័ត៌មានណាដែលគ្មានប្រយោជន៍។
- ឱ្យសិស្សឯទៀតផ្ទៀតផ្ទាត់ និងជួយកែលម្អភ្លាម ប្រសិនបើមានកំហុស។

**ជំណាក់ទី៤** : ការពង្រឹងចំណេះដឹង

- ឱ្យសិស្សយកក្តារឆ្នួនចេញ។

**សំណួមពរ** : ពេលលោកគ្រូ អ្នកគ្រូអានចំណោទ ចូរកូនតាមដានស្តាប់ និងកត់ត្រាលើក្តារឆ្នួនរបស់កូននូវបណ្តាព័ត៌មានទាំងឡាយណាដែលមានប្រយោជន៍ ដើម្បីឆ្លើយនឹងសំណួរ។

-គ្រូបញ្ជាក់សំណូមពរខាងលើនេះឡើងវិញឱ្យបាន ២ ឬ៣ដង។

**ចំណោទ** :

១-ក្នុងថ្នាក់រៀនមួយមានសិស្ស២៨នាក់ ដែលមានអាយុពី១១ ដល់ ១២ឆ្នាំ។ គ្រូបានចែកសៀវភៅទៅឱ្យសិស្សម្នាក់ៗ ៥ក្បាល ដែលមានទម្ងន់ជាមធ្យម ៤៥០ក្រាម ក្នុងមួយក្បាលៗ។ ចូររកចំនួនសៀវភៅទាំងអស់ដែលគ្រូបានចែក។

២-រាល់ពេលព្រឹកលើកលែងតែថ្ងៃអាទិត្យ នៅវេលាម៉ោង ៨:៣០ ពូសុក្រ ដែលមានអាយុ៤៣ឆ្នាំបានទិញទស្សនាវដ្តីមួយច្បាប់។ តម្លៃនៃទស្សនាវដ្តីនេះ គឺ៧០០៛។ តើក្នុងមួយសប្តាហ៍ពូសុក្រត្រូវចំណាយប្រាក់ប៉ុន្មានរៀលដើម្បីទិញទស្សនាវដ្តីរបស់គាត់?

- គ្រូអានចំណោទទី១ ដោយយឺតៗ ច្បាស់ៗពីរ ឬបីដងឱ្យសិស្សស្តាប់ និងកត់ត្រា។
- ឱ្យសិស្សលើកក្តារឆ្នួនបង្ហាញចម្លើយ។
- ឱ្យសិស្សផ្ទៀងផ្ទាត់ និងផ្តល់ចម្លើយរវាងសិស្ស និងសិស្សរួចឱ្យកែកំហុស។
- គ្រូបំពេញបន្ថែម។
- អនុវត្តលំនាំដដែលនេះចំពោះចំណោទទី២។

**ជំហានទី៥** : ការសន្និដ្ឋាន

- គ្រូសួរ : «ក្នុងប្រធានចំណោទ តើបម្រាប់ទាំងអស់សុទ្ធតែមានប្រយោជន៍ជានិច្ច សម្រាប់ដោះស្រាយចំណោទដែរឬទេ ?»
- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់។
- ឱ្យសិស្សឯទៀតផ្ទៀងផ្ទាត់ និងជួយកែលម្អ។
- គ្រូធ្វើសំយោគ រួចបង្ហាញអត្ថបទ «គួរចងចាំ» ដោយសរសេរលើក្ដារខៀន។

**គួរចងចាំ** :

ជាញឹកញាប់ ប្រធានចំណោទតែងតែនាំមកនូវបណ្ដាព័ត៌មានជាច្រើន។ ប៉ុន្តែចូរប្រុងប្រយ័ត្នជានិច្ចថា ព័ត៌មានទាំងអស់ពុំមែនសុទ្ធតែមានប្រយោជន៍ជានិច្ចសម្រាប់ដោះស្រាយចំណោទនោះទេ ដូច្នេះគេត្រូវតែអានប្រធានចំណោទដោយប្រុងប្រយ័ត្ន ដើម្បីជ្រើសរើសតែព័ត៌មានទាំងឡាយណាដែលមានប្រយោជន៍សម្រាប់ឆ្លើយទៅនឹងសំណួរដែលចោទសួរ។ ព័ត៌មានដែលគ្មានប្រយោជន៍ គឺត្រូវឆូតចោលមុននឹងដោះស្រាយចំណោទ។

- ឱ្យសិស្សម្នាក់ ឬពីរនាក់អានអត្ថបទគួរចងចាំនេះ។
- ឱ្យសិស្សចម្លងអត្ថបទ «គួរចងចាំ» ចូលក្នុងសៀវភៅសរសេរ។

IV- **ចម្លើយ**

ការចំណាយរបស់ពូសំណាង

៥0000៛ x ៩ = ៤៥0000៛

ឆូតចោល : ១០ម២, ១៥ម២, ២០សម, ១០០ការ៉ូ

V- **កំណត់សម្គាល់**

ក្រោយពីការសិក្សានៃសលាកបត្រនេះ គ្រូត្រូវដាក់ចំណោទ ជ្រើសរើស១ឬ២ ឱ្យសិស្សធ្វើក្នុងថ្នាក់ភ្លាម ដើម្បីវាយតម្លៃលើការយល់ដឹងរបស់សិស្ស។

ដកស្រង់ដោយលោកស្រី **ប៊ុន សារ៉ន**

**ទម្រង់សិល្បៈទាំង ៧**

ទម្រង់សិល្បៈចែកចេញជា ៧ ទម្រង់សំខាន់ៗគឺ៖

១-សិល្បៈស្ថាបត្យកម្ម ៤-សិល្បៈរបាំ

២-សិល្បៈចម្លាក់ ៦-សិល្បៈអក្សរសិល្ប៍

៣-សិល្បៈគំនូរ ៧-សិល្បៈភាពយន្ត

៥-សិល្បៈតន្ត្រី

សោភ័ណសិល្បៈទាំង ៧ ខាងលើនេះ បង្កើតឡើងសម្រាប់បម្រើឱ្យមនុស្ស និងសង្គមមនុស្សទូទៅ។




# ដឹកនាំ

*(បទពាក្យប្រាំពីរ)*

១- ដឹកនាំស្រមៃទៅថ្ងៃមុខ
ផ្ដើមថ្មី ធ្វើថ្មី ឥតបន្ទូរ
ដឹកនាំគិតទុកក្នុងពេលយូរ
គិតគូរកកើតបង្កើតថ្មី។

២- ដឹកនាំសម្លឹងគ្រប់ជ្រុងជ្រោយ
វិភាគហេតុផលគ្រប់ករណី
ឆ្វេងស្ដាំមុខក្រោយតូចធំក្ដី
ដោះស្រាយសេចក្ដីតាមរឿងរ៉ា។

៣- ដឹកនាំបណ្ដុះទំនុកចិត្ត
ជឿសមត្ថភាព ជឿការងារ
ពង្រីកគំនិតជឿជាក់គ្នា
ជឿការពុះពារមិនមានខ្លាច។

៤- ដឹកនាំប្រើចិត្តស្មើស្មោះស្ម័គ្រ
បេះដូងទូលាយចែកអំណាច
រួសរាយរាក់ទាក់ហើយអង់អាច
មិនខ្លាចបាត់ឈ្មោះបង់អស់កេរ្តិ៍។

៥- ដឹកនាំខំរៀនគ្មានថ្ងៃឈប់
អាន គិត សាកសួរ ខ្វះរិះរេ
រៀនថ្ងៃ រៀនយប់ឥតទំនេរ
ឈប់ខានទំនេរពេលមរណា។

៦- ដឹកនាំធ្វើខ្លួនជាម្ចាស់ពិត
ម្ចាស់រឿង ម្ចាស់ដោះតាមហេតុការណ៍
ម្ចាស់ការ ម្ចាស់គិត ម្ចាស់បញ្ហា
លំបាកម្ដេចម្ដាពុះពារបាន។

៧- ដឹកនាំប្រើចិត្តគិតកែខៃ
ទៅជាឱកាសគ្រប់គ្រងបាន
វិបត្តិកែច្នៃតាមលំអាន
ធានាឱ្យមានការអភិវឌ្ឍ។

៨- រួមគ្នាពង្រឹងភាពដឹកនាំ
រៀនរិះរាវរកអនុវត្ត
តាមក្បួនចេះចាំឱ្យបានស្ទាត់
ដើម្បីអនាគតរីករុងរឿង។

លោក **ពីរ សារ៉ាក់**

# ជំហានទាំងប្រាំ

«បទពាក្យប្រាំពីរ»

១- ជំហានទីមួយបីនាទី ឧស្សាហ៍សម្តី សួរសុខទុក្ខ
ពិនិត្យអនាម័យក្រោយមុខ សិស្សឈប់កត់ទុកឱ្យបានច្បាស់។
២- ជំហានទីពីរ ប្រាំនាទី សួរប្រុសនារីមេរៀនចាស់
តើចេះឬចាំ ឬមិនច្បាស់? សូមមានប្រសាសន៍ណាប្អូនណា។
៣- មេរៀនយើងសិក្សាថ្ងៃមុន លំហាត់នព្វន្តលេខអក្ខរា
តើប្អូនធ្វើហើយ ឬយ៉ាងណា? សូមចេញវាចាប្រាប់គ្រូមក។
៤- បំផុសគំនិតមេរៀនថ្មី... សំណួរពីរបីខ្លីងាយរក
សិស្សយល់ស្តាប់បានណាពន្លក ប្អូនឆ្លើយប្រាប់មកកុំគិតយូរ។
៥- ជំហានទីបី មានសាមសិប នាទីតាំងចិត្ត កុំរអ៊ូ
បើកសៀវភៅអាន តាមលោកគ្រូ នេះទើបគំរូប្រាជ្ញបណ្ឌិត។
៦- ចាប់ផ្តើមស្វែងយល់មេរៀនថ្មី ខិតខំឃ្លាតខ្មីអានហើយគិត
ទាំងក្រុមធំតូចស្វ័យពិនិត្យ រកចម្លើយពិត ត្រៀមបកស្រាយ។
៧- ចាត់តាំងសមាជិកក្នុងក្រុម ពូកែឆ្លាតហំបរិយាយ
ពន្យល់ប្រាប់មិត្តគ្រប់រូបកាយ មិនមានជិនណាយស្រាយឆ្លើយប្រាប់។
៨- ជំហានទីបួន ប្រាំនាទី ប្អូនៗមូលមីរង់ចាំស្តាប់
ពេលគ្រូសួរហើយ គួរប្រញាប់ ស្ទុះស្វាសារស័ព្ទណាកល្យាណ។
៩- យ៉ាងម៉េចមេរៀន យើងថ្ងៃណេះ តើប្អូនចាំចេះ ត្រឹមប៉ុន្មាន?
តើយល់ច្បាស់ទេ ប្អូនគ្រប់ប្រាណ? ត្បិតមេរៀនបានបញ្ចប់ហើយ។
១០-ជំហានទីប្រាំ ពីរនាទី ណែនាំធរីពៅគ្រាណាត្រើយ
ច្បាប់សីលធម៌គ្រូផ្តល់ឱ្យ គ្រាប់កុំខានឡើយ ស្បើយកង្វល់។
១១-ចូរកត់សំណួរយកទៅផ្ទះ ហើសរូតរះសួរបើឆ្ងល់
ជិះកង់ម៉ូតូដើរលើថ្នល់ ស្តាំដៃទើបផ្តល់សុខចម្រើន។

លោក **ឡុប ហុកសេង**
គ្រូបង្រៀនអនុវិ.ព្រែកស្បូវ ខេត្តកំពង់ធំ

# ចរិតជនជាតិខ្មែរ

«បទព្រហ្មគីតិ»

១- យើងជាជនជាតិខ្មែរ ត្រូវចេះថែសម្បត្តិជាតិ
កូនខ្មែរមិនចង្អៀត ត្រូវខ្មីឃ្មាតគ្រប់កិច្ចការ។

២- ជាតិខ្មែរមិនពាលា គួរការពារគ្រប់កាយា
ដូច្នេះត្រូវរក្សា ជួយស្ដាបនាគ្រប់ៗគ្នា។

៣- ទោះបីយើងកុមារ ត្រូវរក្សាគ្រប់វេលា
ពួកយើងត្រូវជួយគ្នា គ្រប់ការងារគ្រប់កម្រិត។

៤- យើងមានចរិតល្អ ហើយស្មោះសរ និងមានចិត្ត
ស្រលាញ់និងអាណិត រាប់អានមិត្តដូចបងប្អូន។

៥- ចរិតរបស់ខ្មែរ មិនគេចកែមិនសាបសូន្យ
កូនខ្មែរជួយបងប្អូន មិនស្រពោនក្នុងចិន្ដា។

៦- ពួកយើងជាមនុស្ស មិនរីងរុះក្នុងកិច្ចការ
យើងមិនត្រូវជក់ម៉ា ឬកញ្ឆាវាមិនល្អ។

៧- ទោះជាយ៉ាងណាក្ដី យើងប្រុសស្រីត្រូវស្មោះសរ
ទោះបីមានឬក្រ ត្រូវបវរគ្រប់ៗគ្នា។

៨- ពួកយើងខិតខំរៀន ស្ដាប់ទូន្មានគ្រប់វេលា
យើងមិនត្រូវខ្ជីខ្ជា ត្រូវការពារដោយកម្លាំង។

៩- យើងមានចិត្តបវរ ដោយត្រេកអរនិងប្រឆាំង
ពួកយើងត្រូវតតាំង កុំប្រឆាំងនឹងជាតិឯង។

១០-យើងត្រូវផឹកទឹកស្អាត ជួយសំអាតផ្ទះសំបែង
ព្រោះបើយើងជាក់ស្ដែង ជាកន្លែងដ៏ល្អមួយ។

១១-ទោះបីជាយ៉ាងណា គ្រប់អាត្មាត្រូវចេះព្រួយ
យើងមានតែខ្លួនមួយ ជាជំនួយដ៏អស្ចារ្យ។

១២-វប្បធម៌ខ្មែរយើងល្អ យ៉ាងបវរនិងអស្ចារ្យ
យើងត្រូវថែរក្សា គ្រប់អក្ខរាដើម្បីជាតិ។

១៣-ពួកយើងមានចិត្តស្មោះ មិនខ្មេះខ្មោះមិនឃ្លៀងឃ្លាត
យើងរក្សាថែមទៀត ឱ្យសាសន៍ជាតិយើងថ្កើងថ្កាន។

**សំណាង សុវណ្ណារ័ត្ន-ហឿន រិទ្ធិសេដ្ឋា-**
**ភីណា សុភ័ក្ត្រ និងយឿន ធារី សិស្សថ្នាក់ទី៩**
សាលាប.ឋ.ស អន្លង់វិល ខេត្តបាត់ដំបង



## ប្រវត្តិឈ្មោះកំពង់ត្រឡាច

នៅក្នុងព.ស ២១១២ គ.ស ១៥៦៨ ម.ស ១៤៩០ ច.ស៩៣០ ឆ្នាំពេងស័រិទ្ធិស័ក សម្ដេចព្រះភគវតីស្រីទេពធីតា មហាចក្រពត្តិ ឧត្តមបរមេតនារាជធានីសោភិលក្ខ័ណា មហាក្សត្រី ជាព្រះអគ្គមហេសីនៃព្រះបរមិន្ទបរមរាជា ជាអម្ចាស់ស្ដេចគង់ព្រះបរមរាជវាំងលង្វែក ទ្រង់ភ្នកព្រះរាជហឫទ័យចង់សាងព្រះកឋិនទានមួយហែរទៅវត្តនៅប្រាសាទអង្គរវត្ត។ ដូច្នេះ សម្ដេចក៏ទ្រង់ក្រាបបង្គំលា សម្ដេចព្រះភស្ដាដើម្បីនាំព្រះកឋិនទានតាមព្រះបំណង។ សម្ដេចព្រះភស្ដាក៏ស្ដេចយល់ព្រម និងស្ដេចព្រះរាជដំណើរទៅជាមួយផង ទើបទ្រង់ត្រាស់បង្គាប់មន្ត្រីខាងជើងទឹកឱ្យត្រៀមការតាមទំនៀម។ ខណៈនោះ ឧកញ៉ាក្រឡាហោម (ជួមន្ត្រីក្រសួងទ័ពជើងទឹក) ចេញមកចាត់ការរាជពិធីជង្ហែតាមជើងទឹកដែលមានទូកមន្ត្រីគ្រប់ក្រសួងសឹងតាំងតាមមុខក្រោយ និងឆ្វេងស្ដាំតាមលំដាប់លំដោយ និងតាមក្រសួង។

លុះដល់ទៅ កំពង់ភ្នំក្រោម ចៅហ្វាយស្រុក និងក្រមការខេត្តបាននាំគ្នាមកថ្វាយបង្គំគាល់យាងព្រះអង្គ និងព្រះអគ្គមហេសីអញ្ជើញស្រីស្នំក្រមបរិពារ ឡើងទៅទតអង្គព្រះកឋិន ហើយក៏ត្រឡប់ក្បួនហែមកព្រះទីនាំងនាវាវិញ។ លុះចេញព្រះទីនាំង និងទូកយោងទូកហែមកដល់កោះស័រិទ្ធិជ័យខេត្តលង្វែក ព្រះបរមបពិត្រទ្រង់ត្រាស់ឱ្យបញ្ឈប់ព្រះរាជដំណើរ ហើយទ្រង់ឡើងគោក ទតអស់វាលបឹងស្ទឹង ព្រៃនានា។ ខណៈនោះសម្ដេចព្រះអគ្គមហេសី ស្រីទេពធីតាទតទៅឃើញប្រាសាទមួយនៅលើកោះនោះ ទ្រង់ក៏សាកសួរចាស់ព្រឹទ្ធាចារ្យដែលនៅទីនោះ។ ចាស់ព្រឹទ្ធាចារ្យក្រាបបង្គំទូលថាៈ ប្រាសាទនោះសាងតាំងអំពីផែនដីព្រះស្រីសុរិយោវង្សក្នុងពេលដែលព្រះអង្គលើកទ័ពទៅផ្ចាញ់ស្ដេចសៀមនៅមហានគរ។ ថាកាលនោះសម្ដេចព្រះអគ្គមហេសីព្រះអង្គជាទីប្រឹក្សាព្រះជ្រៃបានបន់ប្រុងសួងនៅទីនោះសូមឱ្យទីប្រឹក្សាព្រះជ្រៃជាព្រះស្វាមីព្រះអង្គឱ្យបានជ័យជំនះលើទ័ពសត្រូវ ថាបើបានសម្រេចដូចសេចក្ដីប្រាថ្នាមែន ព្រះអង្គនឹងសាងប្រាសាទមួយតម្កល់ព្រះសារីរិកធាតុនៅទីនោះ មួយអន្លើទុកជាព្រះកេរតេរៀងទៅ។ លុះបានឈ្នះសៀម សម្រេចរាបទាបហើយព្រះសុរិយោវង្សព្រះអង្គសាងព្រះវិហារមួយលើភ្នំនោះ ហើយទ្រង់បញ្ញត្តិឱ្យហៅភ្នំនោះថា ភ្នំព្រះទេពីវិញ ព្រោះជាភ្នំដែលព្រះរាជទេពីទ្រង់បានបន់ប្រុងសួង។ ព្រះអង្គបានប្រែឈ្មោះកោះនោះ ពីកោះដំរីទៅជាឈ្មោះកោះប្រជុំស័រិទ្ធិជ័យវិញតាំងពីថ្ងៃនោះមក។ សម្ដេចព្រះអគ្គមហេសី ស្រីទេពីធីតា កាលបានទ្រង់ជ្រាបហើយ ក៏មានព្រះបីតិត្រេកអរសោមនស្សចង់បានប្រាសាទនោះណាស់ ទើបទ្រង់យកសេចក្ដីទៅក្រាបបង្គំទូលព្រះបរមបពិត្រថាៈ

ខ្ញុំម្ចាស់ចង់បានប្រាសាទនេះយកទៅតម្កល់ទុកនៅវត្តព្រះឥន្ទទេពដែលទើបនឹងកសាងហើយដើម្បីនឹងបានតាក់តែងតម្កល់ព្រះបរមសារីរិកធាតុទុកជាព្រះកិត្តិយសតទៅ។

ព្រះបរមនាថ បរមពិត្រ ជាអម្ចាស់ជីវិតលើត្បូង ទ្រង់ជ្រាបហើយ ទ្រង់សព្វព្រះរាជហឫទ័យណាស់ទ្រង់ត្រាស់

បង្គាប់ឱ្យមន្ត្រីប៉ាវតេងស៊ើបសួររកអ្នកមានចំណេះវិជ្ជាណាដែលអាចទទួលអាសាយកប្រាសាទនោះទៅតម្កល់នៅវត្ត ព្រះឥន្ទទេពបាន ថាបើធ្វើបានស្ដេចនឹងប្រទានឱ្យអ្នកនោះធ្វើជាសេនាបតីឱ្យខ្ញុំកំដរឱ្យគោ សេះ ដំរី និងព្រះរាជទ្រព្យ ជប់ៗក្នុងមួយមុខ។

ខណៈនោះមានមនុស្សម្នាក់ឈ្មោះត្រឡាច មានងារកាលពីនៅក្នុងផ្នួសជាពិជ័យព្រឹទ្ធា កាលដើមឡើយធ្វើជាចៅអធិការវត្តពានី។ គាត់បួសបាន៣៥វស្សា តែកាលជាខាងក្រោយមក គាត់មានជំងឺឈឺរាំរ៉ៃខ្លាំងពេក ញាតិញោមបានឱ្យគាត់ចាកសិក្ខាបទ រួចទៅនៅផ្ទះកំណើតគាត់វិញ។ គាត់ចេះសិល្ប៍សាស្ត្រគ្រាន់បើណាស់។ កាលបើបានឮមន្ត្រីប៉ាវតេងស៊ើបសួររកអ្នកមានចំណេះដូច្នេះហើយ គាត់ក៏ចូលទៅក្រាបបង្គំទូលសូមយកអាសានឹងទាក់ប្រាសាទនោះថ្វាយឱ្យបាន។ ព្រះបរមបពិត្រត្រាស់បង្គាប់ទៅមន្ត្រីគ្រប់មុខងារឱ្យធ្វើរានពិធី និងលំដាប់ព្រះរាជពិធីឱ្យព្រះពិជ័យព្រឹទ្ធាតាមបង្គាប់របស់គាត់។ ព្រះពិជ័យព្រឹទ្ធា តាំងពិធីនៅរោងពិធីអស់បីថ្ងៃ ហើយឱ្យយកអំបោះបីសរសៃទៅទាក់កំពូលប្រាសាទស្រូបយកមក។ កំពូលប្រាសាទនោះអណ្ដែតបានមកជិតត្រើយខាងលិចទៅហើយ ព្រមជាមួយនឹងតូរ្យតន្ត្រីលេងគឹកកងកោលាហល។ ខណៈនោះ មានស្រីផើមម្នាក់រត់កាត់ពីមុខរានពិធីនោះ បណ្ដាលឱ្យដាច់ត្រណមអំបោះសីមានោះទៅ ហើយប្រាសាទក៏ធ្លាក់ចុះទៅក្នុងទន្លេត្រង់ទីនោះរៀងរហូតមកដល់សព្វថ្ងៃនេះផ្ទៀងខ្លួនទៅទិសនិរតីបន្តិច។ នៅរដូវប្រាំង ជនផងតែងចុះទៅឈរងូតទឹកលើកំពូលប្រាសាទនោះបាន។ ព្រះពិជ័យព្រឹទ្ធា ដែលត្រណមនោះដាច់ហើយក៏ដឹងខ្លួនថាពុំអាចរស់នៅបានតទៅទៀតទេ ក៏គិតយកកេរ្តិ៍ឈ្មោះទុកឱ្យជាប់ឮវែងឆ្ងាយទៅមុខទៀត ទើបយកសេចក្ដីក្រាបបង្គំទូលព្រះបរមបពិត្រថាៈ សូមឱ្យទីដែលគាត់ធ្វើពិធីនោះមានឈ្មោះហៅថា «កំពង់ត្រឡាច»។ ព្រះបរមបពិត្រព្រះអង្គក៏ទ្រង់ព្រះមេត្តាបញ្ញត្តិឱ្យហៅទីនោះតាមសុំ ទើបប្រជាជនទាំងពួងហៅថា កំពង់ត្រឡាច ជារៀងរហូតមក។ ពិជ័យព្រឹទ្ធា សម្ដែងនូវមន្តអាគមវិជ្ជាការប្រកាសទេវតាទុកថាៈ ឱ្យស្មៅត្រែងដែលជាលំអានអូសប្រាសាទនោះពេលដុះឡើងកាលណាឱ្យទ្រេតទៅទិសនិរតី តាមលំអានដែលអូសប្រាសាទនោះ។ ស្មៅត្រែងនោះក៏ដុះទ្រេតតាមដែលប្រតិស្ឋាននោះរៀងមក។ លុះប្រតិស្ឋានរួចស្រេចហើយ ពិជ័យព្រឹទ្ធាក៏ទទួលអនិច្ចកម្មទៅ។ អាស្រ័យដូចបានរៀបរាប់មកខាងលើនេះ ទើបទីនោះមានឈ្មោះដូច្នេះរៀងមក៕

ដកស្រង់ចេញពីឯកសារមហាបុរសខ្មែរ ដោយលោក **ថែម ផាន**

## រដ្ឋធម្មនុញ្ញ

*រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ចាប់តាំងពីបដិសន្ធិមក មានចំនួន ៦ ដែលបានឆ្លងកាត់រួចមកហើយគឺៈ*

| | |
|---|---|
| *១-រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា* | *(១៩៤៧-១៩៧០)* |
| *២-រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ* | *(១៩៧០-១៩៧៥)* |
| *៣-រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ* | *(១៩៧៥-១៩៧៩)* |
| *៤-រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា* | *(១៩៧៩-១៩៨៩)* |
| *៥-រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា* | *(១៩៨៩-១៩៩៣)* |
| *៦-រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា* | *(១៩៩៣-បច្ចុប្បន្ន)* |

(សកាល)

# ប្រវត្តិពាក្យ «គោកធ្លក»

ប្រទេសខ្មែរយើងដើមឡើយឈ្មោះថា «កម្ពុជៈ» ដែលប្រសិទ្ធិនាមដោយពួកឥណ្ឌាដែលបានចូលមកផ្សព្វផ្សាយពុទ្ធសាសនាក្នុងរវាង២០០ឆ្នាំមុនគ.ស ដោយយកតាមឈ្មោះប្រទេសមួយនៅក្នុងប្រទេសឥណ្ឌា។

នគរ កម្ពុជៈ មានព្រំដែនខាងជើងទល់នឹងប្រទេសចិន ខាងត្បូងទល់នឹងសមុទ្រ ខាងកើតទល់នឹងជួរភ្នំ ខាងលិចទល់នឹងនគរពួក មនៈ(មន)។ ប្រជាជនដែលរស់នៅលើនគរ កម្ពុជៈ ពួកឥណ្ឌាបានប្រសិទ្ធិនាមថា «ខេមរៈ» មានន័យថាអ្នកមានសេចក្ដីសុខមិនខ្វះខាតរស់នៅលើទឹកដីដែលសំបូរដោយសម្បត្តិធម្មជាតិដ៏សំបូរបែប។

សម្ដេចសង្ឃរាជ ជួន ណាត មានសង្ឃដីការថាពួកខេមរៈ នេះហៅខ្លួនឯងថា «ខេមរ»។ អាស្រ័យហេតុនេះហើយបានជាចិនដែលមកដល់នគរភ្នំបានហៅពួកខេមរថា «ចេនឡា»។ ពួកខេមរដែលនៅខាងជើងចិនបានហៅថា ចេនឡាដីគោក ហើយខេមរដែលរស់នៅភាគខាងត្បូងចិនហៅថា ចេនឡាទឹកលិច។

គួរបញ្ជាក់ថា ពួកឥណ្ឌាមិនគ្រាន់តែផ្សព្វផ្សាយលទ្ធិនៃពុទ្ធសាសនាដល់ជនខេមរប៉ុននោះទេ គឺថែមទាំងបង្រៀនជនខេមរឱ្យចេះស្លៀកពាក់ ចេះដាំកប្បាស ចេះត្បាញ ចេះផលិតឧបករណ៍ត្បាញទៀតផង។ល។

ដូចនេះ ជនខេមរចេះស្លៀកពាក់រស់នៅ ជាសង្គមមានអរិយធម៌តាំងពី២០០ឆ្នាំមុនគ.សម្ល៉េះ។ ប៉ុន្តែកន្លងមកមានអ្នកប្រវត្តិសាស្ត្រខ្លះដែលសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រប្រទេសកម្ពុជាមិនបានគិតដិតដល់ និងគ្រប់ជ្រុងជ្រោយបាននិយាយថា «អ្នកនគរគោកធ្លកមិនទាន់ចេះស្លៀកពាក់ទេ រហូតដល់ឥណ្ឌាចូលមកបង្រៀនឱ្យស្លៀកពាក់» ការនិយាយបែបនេះគួរឱ្យអស់សំណើចណាស់ ព្រោះកើតជានគរមានស្ដេចសោយរាជ្យហើយ មិនទាន់ចេះស្លៀកពាក់ បើអញ្ចឹងទាំងស្ដេចទាំងរាស្ត្រស្រាតទាំងអស់គ្នា។

សូមបញ្ជាក់ថា នគរគោកធ្លកកើតក្នុងរវាងសតវត្សទី១ នៃគ.ស ក្រោយឥណ្ឌាចូលមក២០០ឆ្នាំ ចុះ ហេតុអ្វីក៏ថាមនុស្សមិនទាន់ចេះស្លៀកពាក់?

ប៉ុន្តែនគរ កម្ពុជៈ ពុំមានស្ដេចសោយរាជ្យទេ ព្រោះពួកខេមរដែលទទួលឥទ្ធិពលនៃពុទ្ធសាសនាពុំទាន់ត្រូវការស្ដេចទេ។ ពួកគេរស់នៅជាសហគមន៍ក្រោមដំបូលនៃពុទ្ធសាសនាដែលមានព្រះសង្ឃ និងព្រឹទ្ធាចារ្យជាអ្នកគ្រប់គ្រងសហគមន៍នីមួយៗរស់នៅដោយសុខសាន្ត។

លុះដល់សតវត្សទី១នៃគ.ស ទើបមានសហគមន៍ខេមរៈមួយដែលនៅខាងត្បូងជាប់នឹងសមុទ្រ បានទទួលឥទ្ធិពលនៃព្រហ្មញ្ញសាសនាពីប្រទេសឥណ្ឌា។ ដោយមានការបញ្ចុះបញ្ចូលពីពួកព្រាហ្មណ៍ មេសហគមន៍ខេមរៈដែលនៅភាគខាងត្បូងនោះក៏យល់ព្រមបង្កើតជារដ្ឋមួយដែលមានស្ដេចសោយរាជ្យដោយប្រសិទ្ធិនាមថា នគរគោកធ្លកសោយរាជ្យដោយស្ដេចស្រីព្រះនាម សោមា។ តើពាក្យថា គោកធ្លក មានប្រភពចេញពីណា?

ខ្ញុំសូមបំភ្លឺដូចតទៅ កាលខ្ញុំនៅពីក្មេងខ្ញុំរៀននៅសាលាបឋមសិក្សាមានសៀវភៅប្រវត្តិសាស្ត្រខ្មែរសរសេរដោយ «ពុទ្ធសាសនបណ្ឌិត្យ» ដាក់ថា «ព្រះរាជពង្សាវតារខ្មែរ»។ ក្នុងសៀវភៅនោះបាននិយាយថា ប្រទេសកម្ពុជាយើងពីដើមសុទ្ធតែទឹកសមុទ្រ ប៉ុន្តែទន្លេមេគង្គបាននាំដីល្បាប់មកចាក់បំពេញធ្វើឱ្យទឹកសមុទ្រគោកជាបណ្ដើរៗ ហើយក៏មានមនុស្សចូលមករស់នៅជាបន្តបន្ទាប់ រីឯភ្នំទាំងឡាយកាលនោះគឺជាកោះ។ តាមកស្តុតាងបញ្ជាក់ថា ប្រទេសខ្មែរពីដើមជាសមុទ្រខ្មែរ ប៉ុន្តែជាធម្មតាពុំដែលមានទន្លេហូរនាំដីល្បាប់មកចាក់បំពេញសមុទ្របាននោះទេ។

តាមការស្រាវជ្រាវរបស់ពួកអ្នកប្រាជ្ញខាងសាគរវិទ្យាបានឱ្យដឹងថា នៅរវាងសតវត្សទី៣ មុនគ.ស ទឹកសមុទ្របានដកថយជាបន្តបន្ទាប់។ គួរបញ្ជាក់ថា ទឹកសមុទ្របានដកថយជាទូទៅលើពិភពលោក។ មូលហេតុដែលនាំឱ្យទឹកសមុទ្រដកថយនោះគឺមកពីទឹកទៅកកនៅតំបន់ប៉ូលទាំងពីរក្រាស់ខ្លាំងពេក។

ការដកថយទឹកសមុទ្រនេះ បណ្តាលឱ្យផ្ទៃប្រទេសយើងត្រង់ខេត្តកណ្តាល ព្រៃវែង ស្វាយរៀង តាកែវ សព្វថ្ងៃក្លាយទៅជាវាលភក់។ ភក់នេះគឺជាដីល្បាប់ដែលទន្លេមេគង្គហូរនាំមកចាក់រាប់សែនឆ្នាំមកហើយ។

ដោយទន្លេមេគង្គនាំដីល្បាប់មកចាក់ ធ្វើឱ្យវាលភក់គោកដោយដុំៗជាច្រើនកន្លែង ហើយកន្លែងដែលគោកនោះក្រៅពីស្មៅគេឃើញមានដើមឆ្លកដុះច្រូងច្រាងលើដីគោក។ ដូចនេះហើយបានជាមានពាក្យថា គោកឆ្លក តមក។ គួរកត់សម្គាល់ថា មនុស្សជំនាន់នោះពុំបានដឹងថា ទឹកទន្លេមេគង្គហូរនាំដីល្បាប់មកចាក់ទេ។ ម្ល៉ោះគាត់យល់ថា ជាអភូតហេតុដែលមានវត្ថុសក្តិសិទ្ធិអ្វីដ៏អស្ចារ្យបង្កើតឱ្យមានដីដុះឡើងជាបន្តបន្ទាប់ដូចនេះ ចំពោះដើមឆ្លកដែលដុះនៅលើកន្លែងណាដែលគោកនោះមានមូលហេតុដូចតទៅ៖ ឆ្លកជារុក្ខជាតិមានដើមធំដុះក្នុងព្រៃ។ ប៉ុន្តែផ្លែឆ្លកមានជាតិសំឡីនៅខាងក្នុងធ្វើឱ្យគ្រាប់ឆ្លកស្រាលអណ្តែតទឹក។ ម្ល៉ោះហើយពេលជោរទឹកឡើង គ្រាប់ឆ្លកអណ្តែតតាមទឹកទៅទើរលើកន្លែងណាដែលគោកហើយដុះឡើង។ ពួកខេមរាដែលជាបុព្វបុរសខ្មែរសម័យនោះគាត់មិនយល់ពីរឿងហេតុទាំងអស់នេះទេ គឺគាត់យល់ថាជាអភូតហេតុដ៏អស្ចារ្យបង្កើតឡើងដោយវត្ថុសក្តិសិទ្ធិអ្វីមួយ។

ហេតុនេះហើយបានជាពួកខេមរាដែលរស់នៅចុងខាងត្បូង បានប្រសិទ្ធិនាមនគររបស់ខ្លួនថា «នគរគោកឆ្លក»។ ចាប់ពីពេលនោះមកពាក្យថា «គោកឆ្លក» ក្លាយជាពាក្យដែលជាទីសក្ការៈរបស់ពួកខេមរាហូតដល់គេបានកសាងពុទ្ធបដិមា ហើយថ្វាយព្រះនាមថា «ព្រះអង្គគោកឆ្លក» ទៀតផងដែរ។ សព្វថ្ងៃមានក្នុងតំបន់អង្គរក្នុងខេត្តសៀមរាប។

ចំណែកខាងទិសពាយ័ព្យដែលមានខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប និងកំពង់ធំ សព្វថ្ងៃនេះកាលនោះជាផ្ទៃសមុទ្រ ភ្នំទាំងឡាយដូចជាភ្នំសំពៅ ភ្នំគូលែនសព្វថ្ងៃកាលនោះគឺជាកោះ។ យើងយកភ្នំសំពៅជាកស្តុតាង ហេតុអ្វីបានជាភ្នំមានមុខស្រួចដូចមុខសំពៅ? តើមាននរណាទៅជាប់មុខភ្នំសំពៅឱ្យមានមុខស្រួចដូចនេះ? ពុំមានមនុស្សណាទៅធ្វើទេ នេះគឺជាការងាររបស់សមុទ្រនៅពេលដែលទឹកសមុទ្របានដកថយ រលកសមុទ្របានចូលវាយបំបែកបន្តិចម្តងៗរហូតដល់សមុទ្រដកថយផុតអស់។

ផ្ទៃសមុទ្របានរួមមកនៅត្រឹមផ្ទៃទន្លេសាបសព្វថ្ងៃ ប៉ុន្តែពុំមានទទួលដីល្បាប់ពីទន្លេមេគង្គទេ។ ម្ល៉ោះហើយស្ថិតនៅជាលក្ខណៈសមុទ្រដដែល តែមានផ្ទៃតូចៗ។ រៀងរាល់ឆ្នាំ ទឹកភ្លៀងដែលហូរពីតំបន់ភ្នំក្រវាញ ភ្នំដងរែក ចូលទៅក្នុងសមុទ្រនោះ បង្កើតបានជាផ្លូវទឹកយ៉ាងច្រើន ពិសេសស្ទឹងនានាដែលយើងឃើញសព្វថ្ងៃនៅជុំវិញបឹងទន្លេសាប។ ក្នុងមួយឆ្នាំៗទឹកភ្លៀងដែលហូរចូលក្នុងសមុទ្រយ៉ាងច្រើននោះបានរុញច្រានទឹកសមុទ្រឱ្យហូរចេញទៅតាមផ្លូវទឹកនានាដែលធ្វើឱ្យទឹកសមុទ្រអន់ប្រៃបន្តិចម្តងរហូតដល់ទៅជាសាប ហើយគេក៏នាំគ្នាហៅថា «សមុទ្រសាប» ជារៀងមក។

កំណត់ហេតុរបស់លោក ជូ តាក្វាន់ បេសកទូតចិនដែលមកក្រុងអង្គរក្នុងសតវត្សទី១២ បានសរសេរថា «ត្រូវឆ្លងកាត់សមុទ្រសាបជាច្រើនថ្ងៃ មុនទៅដល់ក្រុងអង្គរ»។

ហេតុនេះហើយ បានជាព្រះមហាក្សត្រខ្មែរនិយមមកសាងរាជធានីនៅខាងជើងបឹងទន្លេសាបសព្វថ្ងៃ ពីព្រោះដោយយោងទៅតាមលក្ខណៈភូមិសាស្ត្រប្រទេសឥណ្ឌាដែលខាងជើងមានភ្នំព្រះសុមេរុ (ខ្មែរយើងភ្នំដងរែក) ខាងត្បូងមានមហាសមុទ្រឥណ្ឌា (ខ្មែរយើងមានសមុទ្រសាប) មានទន្លេគង្គាហូរចុះពីភ្នំព្រះសុមេរុចូលទៅក្នុងមហាសមុទ្រ (ខ្មែរយើងមានស្ទឹងដែលហូរធ្លាក់ចុះពីភ្នំដងរែកចូលក្នុងសមុទ្រសាបជាតំណាងទន្លេគង្គា)។

ចុះហេតុអ្វីបានជាសព្វថ្ងៃ វាបាត់ឈ្មោះសមុទ្រសាប ហើយទៅជាទន្លេសាបទៅវិញ?

ក្នុងទសវត្សឆ្នាំ១៩៦០ មានគេសួរសម្តេចសង្ឃរាជ ជួន ណាត ថា ទន្លេសាបពុំមានលក្ខណៈជាទន្លេទេ ហេតុអ្វីបានជាគេហៅថាទន្លេ?

ព្រះអង្គមានសង្ឃដីការតបវិញថា ពីណាពីណីមកគេហៅថា សមុទ្រសាប តែខ្មែរយើងវាល្ងង់។ ពាក្យសៀមថា ថាឡេ មានន័យថា សមុទ្រ។ ដូចនេះសៀមគេថា ថាឡេសាប គឺសមុទ្រសាបនេះឯង។ ប៉ុន្តែខ្មែរយើងហៅតាមគេថា ថាឡេសាបតៗគ្នាដែលក្រោយមកក្លាយជាទន្លេសាបរហូតមកដល់សព្វថ្ងៃនេះ។ លោក **នោល ភុន**

ទំព័រស្ត្រី

# គោលនយោបាយស្ដីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ (ត)

**២.៦ ការធ្វើតេស្តឈាមរកមេរោគអេដស៍**

ស្ថាប័នអប់រំមិនតម្រូវឱ្យបុគ្គលិក ឬយុវជនធ្វើតេស្តឈាមជាចាំបាច់ដើម្បីទទួលបានការងារ និងការចុះឈ្មោះចូលរៀនបន្ត ការធ្វើការងារ ឬសកម្មភាពអប់រំផ្សេងៗទៀតទេ។

មានការទទួលស្គាល់ថា បណ្ដាញមណ្ឌលធ្វើតេស្តឈាម និងផ្ដល់ប្រឹក្សាដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់របស់រដ្ឋត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស។ ក្រសួងនឹងលើកទឹកចិត្តបុគ្គលិក និងយុវជនក្មេងៗឱ្យប្រើប្រាស់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងឱ្យពួកគេយល់ពីគោលបំណង និងតម្លៃនៃការដឹងពីស្ថានភាពមេរោគអេដស៍។

«**ការធ្វើតេស្តមេរោគអេដស៍ ឬជំងឺអេដស៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងត្រូវមានការយល់ព្រមជាមុនពីសាម៉ីជនផ្ទាល់។ ចំពោះសាម៉ីជនអនីតិជនតម្រូវឱ្យមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាណាព្យាបាលស្របច្បាប់។ បើការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាណាព្យាបាលស្របច្បាប់កុំអាចធ្វើបាន ការធ្វើតេស្តមេរោគអេដស៍ ឬជំងឺអេដស៍អាចប្រព្រឹត្តទៅបានដោយគ្រាន់តែមានការព្រមព្រៀងពីអនីតិជន ប្រសិនបើការធ្វើតេស្តនេះផ្ដល់អត្ថប្រយោជន៍ផ្ទាល់ចំពោះអនីតិជននោះ។ ចំពោះជនវិកលចរិត ត្រូវត្រូវយកចិត្តទុកដាក់**»។

(ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលមេរោគអេដស៍ និងជំងឺអេដស៍ជំពូកទី៤ មាត្រា១៩)។

**២.៧ ការធានារក្សាការសម្ងាត់**

រាល់របាយការណ៍សុខភាព កំណត់ត្រាសុខភាព និងឯកសារផ្សេងៗដែលទាក់ទងនឹងបុគ្គលិក ឬសិស្ស និស្សិតមានផ្ទុកមេរោគអេដស៍ គួរតែរក្សាទុកដោយសម្ងាត់នៅកន្លែងដែលមានសុវត្ថិភាព។ អាចមើលឯកសារទាំងនោះលុះណាតែស្របតាមបញ្ញត្តិផ្សេងៗនៃក្រមអនុវត្តន៍របស់អង្គការពលកម្មអន្តរជាតិស្ដីពីការការពារទិន្នន័យបុគ្គលរបស់អ្នកធ្វើការងារ (ឧបសម្ព័ន្ធ៥)។ មានតែអ្នកដែលមានលិខិតអនុញ្ញាតពីនិយោជិត សិស្ស មាតាបិតា ឬបុគ្គលិកពេទ្យសង្គ្រោះបន្ទាន់ប៉ុណ្ណោះ ដែលអាចមើលកំណត់ត្រាទាំងនេះបាន។

ព័ត៌មានទាក់ទងនឹងស្ថានភាពមេរោគអេដស៍ និងមិនបញ្ចូលទៅក្នុងកំណត់ត្រាអប់រំរបស់យុវជនទេ។ ការរក្សាការសម្ងាត់ក៏គួរមានការធានាតាមរយៈការផ្ដល់បរិយាកាសដោយឡែក សម្រាប់ការសម្ភាសន៍បុគ្គលម្នាក់ៗ និងតាមរយៈការរៀបចំឱ្យមានការថែទាំ និងគាំទ្រដល់អ្នកពាក់ព័ន្ធ។ សំបុត្រពេទ្យមិនចាំបាច់បញ្ជាក់ស្ថានភាពមេរោគអេដស៍របស់និយោជិត ឬសិស្ស និស្សិតឡើយ។

ប្រសិនបើក្រសួង ឬបុគ្គលិកក្រសួងណាម្នាក់ដឹងអំពីលទ្ធផលនៃការធ្វើតេស្តឈាមនោះ ព័ត៌មាននេះនឹងត្រូវរក្សាការសម្ងាត់ មិនត្រូវផ្សព្វផ្សាយទាំងក្នុង ទាំងក្រៅក្រសួង លើកលែងតែមានតម្រូវការពីច្បាប់ ឧទាហរណ៍ការផ្ដល់ស្ថិតិអនាមិក និងទិន្នន័យស្ដីពីអត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍។

ប្រកាសផ្សព្វផ្សាយគួរតែធ្វើឡើងដោយស្ម័គ្រចិត្ត។ ប្រសិនបើព័ត៌មានស្ដីពីស្ថានភាពមេរោគអេដស៍របស់បុគ្គលិក ឬសិស្ស និស្សិតត្រូវផ្សព្វផ្សាយនោះ ការផ្សព្វផ្សាយគួរទទួលបានការឯកភាពជាលាយលក្ខណ៍អក្សរពីម្ចាស់ព័ត៌មាន។

«**អ្នកមានមេរោគអេដស៍ ឬជំងឺអេដស៍ ត្រូវទទួលបានការរក្សាការសម្ងាត់។ អ្នកមានអាជីពផ្នែកវេជ្ជសាស្ត្រ កម្មករ និយោជិក ទីភ្នាក់ងារជ្រើសរើសបុគ្គលិកនានា ក្រុមហ៊ុនធានារ៉ាប់រង អ្នកបញ្ចូលទិន្នន័យ អ្នករក្សាសំណុំឯកសារទាក់ទងនឹង**

**មេរោគអេដស៍ ឬជំងឺអេដស៍ និងអ្នកដែលមានភារកិច្ចផ្សេងៗទៀត ត្រូវបានទទួលការណែនាំឱ្យយកចិត្តទុកដាក់ពីការរក្សាការសម្ងាត់នៅក្នុងទំនាក់ទំនងការងារ ជាពិសេសអត្តសញ្ញាណ និងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកមានមេរោគអេដស៍ ឬជំងឺអេដស៍**»។

(ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលមេរោគអេដស៍និងជំងឺអេដស៍ ជំពូកទី៧ មាត្រា៣៣)។

**២.៤ ការងារថែទាំ ព្យាបាលនិងគាំទ្រ**

១-ការជ្រើសរើស និងការអនុញ្ញាតឱ្យចូលរៀនៈ

មិនគួរចាត់ទុកមេរោគអេដស៍ ជាផ្នែកមួយនៃនីតិវិធីផ្តល់ការងារ ឬអនុញ្ញាតឱ្យចូលសិក្សា ឬផ្នែកមួយនៃការសម្រេចចិត្តសម្រាប់បុគ្គលណាម្នាក់ ដែលដាក់ពាក្យចូលក្នុងស្ថាប័នអប់រំដើម្បីបំរើការងារ ឬសិក្សាឡើយ។

**២-សិទ្ធិបុគ្គលិក វិជ្ជាជីវៈ និងសិទ្ធិក្នុងការសិក្សា**

**ក.បុគ្គលិក** : បុគ្គលិកដែលមានផ្ទុកមេរោគអេដស៍មិនគួររងគ្រោះដោយសារតែការរើសអើង លើការសម្រេចចិត្តទាក់ទងនឹងសុវត្ថិភាពការងារ ការកាន់មុខតំណែង ការបន្តកិច្ចសន្យាថ្មីនៃកិច្ចសន្យាការងាររយៈពេលវែងឱកាសអភិវឌ្ឍវិជ្ជាជីវៈ ឬការដំឡើងឋានៈនោះឡើយ។ បុគ្គលិកទាំងនោះអាចត្រូវផ្លាស់ប្តូរមុខតំណែងការងារទៅតាមកំណត់របស់គ្រូពេទ្យឱ្យស្របទៅតាមស្ថានភាពជាក់ស្តែង ឬផ្លាស់ប្តូរពីភារកិច្ចជាក់លាក់ណាមួយ ដែលអាចចម្លងគ្រោះថ្នាក់នៃការឆ្លងមេរោគដល់បុគ្គលិក ឬមនុស្សផ្សេងទៀត។ ការផ្លាស់ប្តូរបែបនេះគួរធ្វើឡើងដោយមានការពិគ្រោះពិភាក្សាជាមួយបុគ្គលិកដែលមានផ្ទុកមេរោគអេដស៍ និងអាចទទួលបាននីតិវិធីផ្តល់សារទុក្ខដូចមានចែងក្នុងបញ្ញត្តិនៃគោលនយោបាយ។

**ខ.សិស្ស និស្សិត** : អ្នកគ្រប់គ្រង និងគ្រូបង្រៀន គួរគោរពតាមគោលនយោបាយ និងនីតិវិធីដែលបានបង្កើតឡើងសម្រាប់សិស្ស និស្សិតដែលមានបញ្ហាសុខភាពពុំរ៉ៃ។ មេរោគអេដស៍មិនមែនជាបុព្វហេតុក្នុងការបដិសេធការផ្តល់ឱកាសសិក្សាជាធម្មតា ឬការបំបែកក្រុមនៅតាមស្ថាប័នអប់រំទេ។

ប្រសិនបើសិស្ស និស្សិតគ្មានសមត្ថភាព និងមិនអាចបន្តការអប់រំជាធម្មតាទេ ស្ថាប័នអប់រំគួរអនុវត្តគោលការណ៍ផ្តល់កន្លែងស្នាក់នៅសមស្របដើម្បីជួយសម្រាលបន្ទុករៀនសូត្រ ដូចជាក្នុងករណីមានជំងឺធ្ងន់ធ្ងរ ពិការភាព ឬអសមត្ថភាព។ ប្រសិនបើអាចធ្វើបាន គ្រប់ស្ថាប័នអប់រំគួរសហការជាមួយសេវាអប់រំ និងបណ្តាញគាំទ្រមេរោគអេដស៍ក្នុងសហគមន៍ ដើម្បីផ្តល់ការសិក្សាដល់ផ្ទះដល់ជនទាំងនោះ។

«រដ្ឋត្រូវធានាឱ្យអ្នកមានមេរោគអេដស៍ ឬជំងឺអេដស៍ ទទួលបាននូវសេវាថែទាំសុខភាពបឋមដោយបង់ថ្លៃតាមបណ្តាញសុខាភិបាលទាំងអស់របស់រដ្ឋ និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន»។ (ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលមេរោគអេដស៍ និងជំងឺអេដស៍ជំពូកទី៥ មាត្រាទី២៦)។

**៣.ការថែទាំ និងការព្យាបាល**

ក្នុងនាមជាអ្នកដឹកនាំ ក្រសួងទទួលស្គាល់ថា ក្រសួងត្រូវតែធ្វើការងារគ្រប់បែបយ៉ាងដែលសមស្រប ដើម្បីថែទាំ និងគាំទ្របុគ្គលិករបស់ខ្លួនដែលមានផ្ទុកមេរោគអេដស៍ដូចជាការគាំទ្រអ្នកជំងឺ(១)ដទៃទៀតដែរ។

ស្ថាប័នអប់រំគួរផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់សេវាសុខភាព និងកម្មវិធីរស់នៅប្រកបដោយសុខភាព រួមមានការចែកចាយស្រោមអនាម័យ និងថ្នាំពន្យារជីវិត ឬការព្យាបាល សម្រួលដល់ការកាត់បន្ថយរោគសញ្ញាដែលទាក់ទងនឹងមេរោគអេដស៍ ការឆ្លងជំងឺឱកាសនិយមផ្សេងៗ ដំបូន្មានពីអាហារូបត្ថម្ភ ការផ្តល់អាហារូបត្ថម្ភបន្ថែម និងវិធានការកាត់បន្ថយការតានតឹងចិត្ត។ (នៅមានត)

ដកស្រង់ដោយលោក **ប៉ែន គុណា**

(១)ការទទួលខុសត្រូវទាំងនេះមានចែងក្នុងផ្នែកគោលការណ៍ទី៣ៈ និងសិទ្ធិ និងការទទួលខុសត្រូវរបស់គោលនយោបាយនេះ។ គោលការណ៍ទាំងនេះមានចែងក្នុងក្រមអនុវត្តន៍របស់អង្គការពលកម្មអន្តរជាតិ ដោយចាត់ទុកថា «ការងារសមស្រប» ហើយការទទួលខុសត្រូវនេះរៀបរាប់ពីវិធានការដែលត្រូវអនុវត្តដោយនិយោជក ឬស្ថាប័នដើម្បីរក្សា និងផ្តល់ឱ្យបុគ្គលិកនូវការងារសមស្រប ដោយផ្អែកលើលក្ខខណ្ឌសមស្រប និងតាមលទ្ធភាពអាចធ្វើបាន និងផ្អែកលើការវាយតម្លៃតាមការវាយតម្លៃវេជ្ជសាស្ត្រសុខភាព។




## តើលោកគ្រូ អ្នកគ្រូដឹងឬទេ?

### អ្នកប្រើពាក្យ «ប្រលោមលោក» មុនគេ

ក្នុងវចនានុក្រមសម្ដេច **ជួន ណាត** បានពន្យល់ថា ប្រលោមលោកគឺជារឿងប្រលោមចិត្តមនុស្ស គឺរឿងដែលអ្នកតែងប្រតិដ្ឋប្រដូចរឿង ដោយឥតមានច្បាប់ដើមជាការណ៍ពិតប្រាកដ ជាគោលចារឹកឡើយ។ ប្រលោមលោកនេះក្នុងសម័យពីដើមហៅ សាស្ត្រល្បែង ឬរឿងល្បែង តែងនិពន្ធជាពាក្យកាព្យ ដូចជាសាស្ត្រាស័ង្ខសិល្ប៍ជ័យ លក្ខិណវង្ស ហង្សយន្ត ជិនវង្សជាដើម។

ប្រលោមលោកមុនដំបូងគេបង្អស់ ក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ គឺរឿង «ទឹកទន្លេសាប» និពន្ធដោយលោក គឹម ហាក់ ឬធេង ហាក់ នៅឆ្នាំ១៩៣៩ បោះពុម្ពផ្សាយនៅឆ្នាំ១៩៤១ (សូមអានទស្សនាវដ្ដីគ្រូបង្រៀនលេខ ៤១)។

ប៉ុន្តែពាក្យ «ប្រលោមលោក» គឺកវី នូ កន ជាអ្នកប្រើពាក្យនេះមុនគេ នេះបើយោងតាមសៀវភៅ «អក្សរសិល្ប៍ខ្មែរ សតវត្សទី២០» របស់លោក ឃីង ហុកឌី។ ប្រលោមលោកត្រូវនឹងពាក្យបារាំងថា Roman សំដៅដល់ប្រភេទរឿងជាពាក្យរាយធម្មតា មិនមែនជារឿងល្បែងដែលខ្មែរយើងពីបុរាណតែងតែសរសេរជាពាក្យកាព្យនោះឡើយ។

នូ កន កើតនៅឆ្នាំ១៨៧៤ នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងគ្រួសារកសិករឪពុកឈ្មោះ នូ ម្ដាយឈ្មោះ អ៊ុក។ វ័យបាន៩ឆ្នាំ កុមារ **នូ កន** បានទៅស្នាក់សិក្សានៅវត្តអង្គត្នោត ឃុំនិងស្រុកដដែល ក្នុងសំណាក់ចៅអធិការនាម អ៊ិន។ លុះដល់វ័យ១៤ឆ្នាំ បានសាងផ្នួសជាសាមណេរ ហើយបានលាចាកសិក្ខាបទនៅឆ្នាំបន្ទាប់។ អាយុ១៧ឆ្នាំ យុវជនអនាគតកវីបណ្ឌិតយើង បានទៅធ្វើជាស្មៀនចៅហ្វាយខេត្តទ្រាំង (សព្វថ្ងៃកម្ពុជាក្រោម ឬវៀតណាមខាងត្បូង)។ ឆ្នាំ១៨៩១ លោកបានផ្លាស់ទៅធ្វើការក្នុងព្រះបរមរាជវាំងក្នុងក្រុមព្រះអាល័ក្ខណ៍ នារជ្ជកាលព្រះករុណា នរោត្តម។ ៤ឆ្នាំក្រោយមក ព្រះករុណាបានផ្លាស់លោកឱ្យទៅធ្វើការផ្នែកសុរិយោដី និងក្រសួងរតនាគារ ពេលនោះអ្នកឧកញ៉ាពិភក្តិទិព្វរាជ **ម៉ម** បានតាំងងារលោកជា ម៉ឺនភក្តីអក្សរ។ ឆ្នាំ១៩០២ លោកបានប្រឡងជាប់ចំណាត់ថ្នាក់លេខ១ ជាអ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រ។ លោកបានត្រូវចាត់ឱ្យទៅរៀនបន្តនៅប្រទេសបារាំង លុះត្រឡប់មកវិញលោកទទួលបានតំណែងជាបន្តបន្ទាប់ជាច្រើនគឺៈ ចៅហ្វាយខេត្តពញាលឺ ចៅហ្វាយខេត្តស្ទឹងត្រែង ឧកញ៉ាសភាមន្ត្រីសាលាឧទ្ធរណ៍ ឧកញ៉ាពិភក្តិវិនិច្ឆ័យ ចៅហ្វាយខេត្តកំពង់សៀម កំពង់ធំ ឧកញ៉ាមហាវិនិច្ឆ័យចាងហ្វាងសាលាឧទ្ធរណ៍ ក្រុមរដ្ឋប្បវេណី ឧកញ៉ាវិបុលរាជភក្ដីឈ្មួយសេនាបតីក្រសួងជើងទឹកថ្នាក់ឧត្តមមន្ត្រីលេខ២ ឧកញ៉ាវិបុលរាជភក្ដីឈ្មួយក្រសួងពាណិជ្ជការ។ លោកបានចូលនិវត្តន៍នៅឆ្នាំ១៩៣១ ហើយបានឈរឈ្មោះ និងជាប់ជាតំណាងរាស្ត្រ

មណ្ឌលកោះសូទិន ក្នុងគណៈបក្សប្រជាធិបតេយ្យនៅឆ្នាំ១៩៤៦។

ឧកញ៉ាកវីបណ្ឌិត **នូ កន** បានអនិច្ចកម្មនៅឆ្នាំ១៩៤៧។ តែអ្នកនិពន្ធ **សុទ្ធ ប៉ូលីន** ដែលត្រូវជាចៅរបស់គាត់ បានសរសេរថា បណ្ឌិតរូបនេះបានអនិច្ចកម្មនៅឆ្នាំ១៩៥០។ តាមឯកសាររបស់លោក **លី ធាមតេង** អ្នកនិពន្ធដែលមានឈ្មោះល្បីអះអាងថា លោក នូ កន អនិច្ចកម្មនៅឆ្នាំ១៩៤៧ដែរ សៀវភៅអក្សរសិល្ប៍ខ្មែរសតវត្សទី២០ របស់លោក **យឹង ញុតនី** បានកត់សំគាល់ថា យើងគប្បីយកតាមឯកសាររបស់លោក លី ធាមតេង ព្រោះជាឯកសារសិក្សាក្រោយ មានការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ។ រីឯរូបគំនូរពាក់កណ្ដាលខ្លួនរបស់លោក នូ កន តាំងនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត ដាក់ថា «នូ កន ១៨៧៤-១៩៤៧»។

ស្នាដៃរបស់លោករួមមាន៖

- ទាវឯក (រឿងល្បែង)
- តុងឈិន (ពាក្យរាយ)
- ពិម្ពានិព្វាន
- សាមកុក (បកប្រែ)
- អ៊ីណាវ បុស្បា (បកប្រែ)...

គួរកត់សម្គាល់ថា លោក នូ កន ពុំចេះភាសាចិនទេ ប៉ុន្តែក៏ដូចបញ្ញវ័ន្តខ្មែរឯទៀតៗនាសម័យនោះដែរ គឺលោកចេះភាសាសៀមយ៉ាងច្បាស់៕

**លោក យស់ អ៊ាង**

೩🕮೫

## សារធាតុប្រវត្តិ

*- ព្រះបាទត្រសក់ផ្អែមមានបុត្រពីរអង្គ គឺ ព្រះបាទបរមនិព្វានបទ និងព្រះសទ្ធានរាជា*

*- ព្រះបរមនិព្វានបទ មានបុត្រមួយអង្គគឺ ព្រះស្រីសុរិយោវង្សទី១*

*- ព្រះសុទ្ធានរាជា មានបុត្រពីរអង្គគឺ ព្រះលំពង្សរាជា និងព្រះស្រីសុរិយោទ័យ*

*- ព្រះលំពង្សរាជា មានបុត្រពីរអង្គគឺ ព្រះបរមរាមា និងព្រះធម្មាសោករាជ*

*- ព្រះស្រីសុរិយោទ័យ មានបុត្រមួយអង្គគឺ ព្រះស្រីសុរិយោវង្សទី២*

*- ព្រះធម្មាសោករាជ មានបុត្រមួយអង្គគឺ ព្រះបរមសោករាជ*

*- ព្រះស្រីសុរិយោវង្សទី២ មានបុត្រមួយអង្គគឺ ព្រះពញាយ៉ាត។*

*ដូចនេះបើរាប់បញ្ច្រាសឡើងវិញ ឃើញថា*

*- ព្រះបាទពញាយ៉ាត ត្រូវជាបុត្ររបស់ព្រះស្រីសុរិយោវង្សទី២ ត្រូវជាចៅរបស់ព្រះស្រីសុរិយោទ័យ ត្រូវជាចៅទួតរបស់ព្រះសន្ធានរាជា ត្រូវជាចៅលួតរបស់ព្រះបាទត្រសក់ផ្អែម*

*- រីឯព្រះបរមសោករាជ គឺត្រូវជាបុត្ររបស់ព្រះធម្មាសោករាជ ត្រូវជាចៅរបស់ព្រះលំពង្សរាជា ត្រូវជាចៅទួតរបស់ព្រះសន្ធានរាជា ត្រូវជាចៅលួតរបស់ព្រះបាទត្រសក់ផ្អែម។*

*ដូច្នេះ ព្រះបាទពញាយ៉ាត និងព្រះបរមសោករាជនេះ ត្រូវជាបងប្អូនជីលួតមួយនឹងគ្នា។*

*ប្រលោមលោកប្រវត្តិសាស្ត្រ «ព្រះបាទពញាយ៉ាត» ១៩៦៦*

**នុយ ឡុត**

# ក្រុង ស្រុក ខណ្ឌ-ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២

ក្នុងលទ្ធផលជំរឿនទូទៅនូវប្រជាការស្ត្របស់ប្រទេសកម្ពុជាឆ្នាំ២០០៨ ព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន១ ខេត្តចំនួន២៣ ស្រុកចំនួន១៥៩ ខណ្ឌចំនួន៨ ក្រុងចំនួន២៦ ឃុំចំនួន១៤១៧ សង្កាត់ចំនួន២០៤ និងភូមិចំនួន១៤០៧៣។

ក្នុងរវាងចុងឆ្នាំ២០០៨ និងឆ្នាំ២០១១ រាជរដ្ឋាភិបាលបានបង្កើតឃុំសង្កាត់ថ្មីចំនួន១២ និងខណ្ឌថ្មី១ ហៅថាខណ្ឌពោធិសែនជ័យដោយកាត់យកឃុំចំនួន១៣ ពីខណ្ឌដង្កោ។

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តកណ្តាល និងរាជធានីភ្នំពេញដោយកាត់យកឃុំចំនួន២០ នៃខេត្តកណ្តាលមករាជធានីភ្នំពេញ (ព្រះរាជក្រឹត្យលេខនស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ដើម្បីពង្រីកផ្ទៃដីខណ្ឌដង្កោ ខណ្ឌមានជ័យ ខណ្ឌឫស្សីកែវ និងខណ្ឌសែនសុខ។

បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានខណ្ឌកើនដល់ចំនួន៩ និងសង្កាត់កើនដល់២២៧ និងឃុំថយមកត្រឹម១៤០៦។ ជាសរុបមានរាជធានី១ ខេត្ត២៣ ក្រុងស្រុកខណ្ឌ១៩៤ និងឃុំសង្កាត់១៦៣៣។

**I- ការបង្កើតឃុំ-សង្កាត់ថ្មីចំនួន១២**

ក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលបានបង្កើតឃុំសង្កាត់ថ្មីចំនួន១២ ដោយកាត់ភូមិពីឃុំចាស់នៃស្រុកចំនួន៨ ក្នុងខេត្តចំនួន៦។

១-ខេត្តព្រះវិហារក្នុងស្រុកជាំក្សាន្តបង្កើតឃុំថ្មីពីរគឺ ឃុំមរកត ដោយកាត់ភូមិចំនួន៦ ពីឃុំទឹកក្រហម និងឃុំស្រអែម ដោយកាត់ភូមិចំនួន៧ពីឃុំកន្ទួត។

២-ខេត្តបាត់ដំបង បង្កើតឃុំថ្មីចំនួន៦ គឺក្នុងស្រុករុក្ខគិរី បង្កើត៣ឃុំ គឺឃុំបាសាក់ ដោយកាត់ភូមិចំនួន៥ ពីឃុំព្រែកជីក ឃុំមុខរាហ៍ និងឃុំស្តុកប្រវឹក។ ស្រុកបវេល បង្កើតឃុំថ្មីចំនួន២គឺ ឃុំឃ្លាំងមាស និងឃុំបឹងប្រាំ។ ស្រុករតនមណ្ឌលបង្កើតឃុំថ្មីចំនួន ១ គឺឃុំស្មើសង្ហារ។

៣-ខេត្តព្រះសីហនុ បង្កើតឃុំថ្មី១ក្នុងស្រុកស្ទឹងហាវ គឺឃុំកែវផុស។

៤-ខេត្តបន្ទាយមានជ័យ បង្កើតសង្កាត់ថ្មី១ក្នុងក្រុងប៉ោយប៉ែត គឺសង្កាត់ផ្សារកណ្តាល។

៥-ខេត្តកំពត បានបង្កើតឃុំថ្មី១ក្នុងស្រុកឈូក គឺឃុំគេជោអភិវឌ្ឍ។

៦-ខេត្តរតនគិរី បង្កើតសង្កាត់ថ្មី១ក្នុងក្រុងបានលុង គឺសង្កាត់បឹងកន្សែង។

៧-ខេត្តកែប បានបញ្ចូលឃុំអូរក្រសាររបស់ស្រុកដំណាក់ចង្អើរមកក្រុងកែបវិញជាសង្កាត់អូរក្រសារ។

**II- ឈ្មោះសង្កាត់តាមក្រុង**

សង្កាត់តាមក្រុងទាំង២៦ មានចំនួន១៣១សង្កាត់។

១-ក្រុងសួងកាត់យកឃុំសួង និងវិហារលួងពីស្រុកត្បូងឃ្មុំមាន២សង្កាត់ គឺសង្កាត់សួង និងសង្កាត់វិហារលួង។

២-ក្រុងសំរោងខេត្តឧត្តរមានជ័យមាន ៥ សង្កាត់គឺបន្សាយរាក់ បុស្សរ៍ កូនក្រៀល សំរោង និងអូរស្មាច់។

៣-ប្តូរខណ្ឌមិត្តភាព ជាក្រុងព្រះសីហនុ មាន ៥ សង្កាត់: សង្កាត់លេខ១ លេខ២ លេខ៣ លេខ៤ និងសង្កាត់កោះរ៉ុង។

៤-ខណ្ឌប៉ៃលិន ទៅជាក្រុងប៉ៃលិន មាន ៤ សង្កាត់: សង្កាត់ប៉ៃលិន បរយ៉ាខា ទួលល្វា និងអូរតាវ៉ៅ។

៥-ក្រុងកែប ប្តូរពីខណ្ឌកែប មាន ៣ សង្កាត់: សង្កាត់កែប ព្រៃធំ និងអូរក្រសារ។

៦-ក្រុងព្រះវិហារ មាន ២ ឃុំ កាត់ពីស្រុកត្បែងមានជ័យ: សង្កាត់កំពង់ប្រណាក និងប៉ាលហាល។

៧-ក្រុងស្វាយរៀង កាត់យកឃុំសង្ឃ័រពីស្រុកស្វាយទាប ឃុំតៀពីស្រុកកំពង់រោទិ៍ និងឃុំចកពីស្រុកស្វាយជ្រំ បន្ថែមទៀត។ មាន៧សង្កាត់ : សង្កាត់ស្វាយរៀង ព្រៃឆ្លាក់ គយត្របែក ពោធិតាហោ សង្ឃ័រ ស្វាយតឿ និងចក។

៨-ក្រុងស្ទឹងសែន កាត់យកចេញឃុំ៣ពីក្រុងស្ទឹងសែន : ឃុំត្បូងក្រពើឱ្យស្រុកសន្ទុក ឃុំក្ដីដូង និងឃុំព្រៃគុយ ទៅស្រុកកំពង់ស្វាយ។ មាន ៨ សង្កាត់ : សង្កាត់កំពង់រទេះ កំពង់ធំ ដំរីជាន់ខ្លា អូរកន្ធរ កំពង់ក្របៅ ព្រៃតាហ៊ូ អាចារ្យលាក់ និងសង្កាត់ស្រយ៉ូវ។

៩-ក្រុងសៀមរាប កាត់យកឃុំបន្ថែមពីស្រុកពួក : ឃុំក្របីរៀល ឃុំទឹកវិល និងឃុំអំពិលពីស្រុកប្រាសាទបាគង។ មាន ១៣ សង្កាត់ : សង្កាត់ស្រង៉ែ ស្វាយដង្គំ គោកចក សាលាកំរើក នគរធំ ជ្រាវ ចុងឃ្នៀស សំបួរ សៀមរាប ស្លក្រាម ទឹកវិល ក្របីរៀល និងសង្កាត់អំពិល។

១០-ក្រុងសិរីសោភ័ណ កាត់យកឃុំឫស្សី ពីសិរីសោភ័ណឱ្យទៅព្រះនេត្រព្រះ។ មាន ៧ សង្កាត់ : សង្កាត់កំពង់ស្វាយ កោះពងសត្វ ម្កាក់ អូរអំបិល ភ្នៀត ព្រះពន្លា និងទឹកថ្លា។

១១-ក្រុងពោធិសាត់ប្តូរពីស្រុកសំពៅមាសដែលបានកាត់ឃុំកោះជុំទៅឱ្យស្រុកកណ្ដៀង និងកាត់យកឃុំបន្ទាយដីមកស្រុកសំពៅមាសវិញ។ មាន ៧ សង្កាត់ : សង្កាត់ផ្ទះប្រៃ លលកស ព្រៃញី ចំរើនផល ស្វាយអាត់ រលាប និងបន្ទាយដី។

១២-ស្រុកព្រៃវែង ប្តូរជាស្រុកស្វាយអន្ទរ។ ក្រុងព្រៃវែង កាត់យកឃុំ ៣ ពីស្រុកកំពង់លាវ។ មាន ៣ សង្កាត់ : កំពង់លាវ បារាយណ៍ និងសង្កាត់ជើងទឹក។

១៣-ស្រុកក្រចេះ ប្តូរឈ្មោះជាស្រុកចិត្របុរី។ ក្រុងក្រចេះ កាត់យកឃុំ ៥ ពីស្រុកចិត្របុរី។ មាន ៥ សង្កាត់ : សង្កាត់អូរឫស្សី ក្រចេះ កោះទ្រង់ ក្រគរ និងរកាកណ្តាល។

១៤-ក្រុងប៉ោយប៉ែត កាត់យកឃុំប៉ោយប៉ែត និងឃុំនិមិត្តពីស្រុកអូរជ្រៅ។ មាន ៣ សង្កាត់ : ប៉ោយប៉ែត អូរជ្រៅ និងសង្កាត់ផ្សារកណ្តាល។

១៥-ក្រុងបាវិតកាត់យកឃុំពីស្រុកចន្ទ្រាចំនួន ៤ ឃុំ : បាវិត ព្រៃអង្គុញ ប្រាសាទ និងបាទី និងពីស្រុកស្វាយទាប គឺឃុំច្រកម្ទេស។ មាន ៥ សង្កាត់ : សង្កាត់បាវិត ព្រៃអង្គុញ ប្រាសាទ បាទី និងសង្កាត់ច្រកម្ទេស។

១៦-ក្រុងតាខ្មៅ មាន ៦ សង្កាត់ : សង្កាត់តាក្ដុល ព្រែកឫស្សី ដើមមៀន តាខ្មៅ ព្រែកហូរ និងកំពង់សំណាញ់។

១៧-ក្រុងស្ទឹងត្រែង មាន ៤ សង្កាត់ : ស្ទឹងត្រែង ស្រះឫស្សី ព្រះបាទ និងសាមគ្គី។

១៨-ក្រុងខេមរភូមិន្ទ ប្តូរពីស្រុកស្មាច់មានជ័យ មាន ៣ សង្កាត់ : ស្ទឹងវែង ដងទង់ និងស្មាច់មានជ័យ។

១៩-ក្រុងសែនមនោរម្យ មាន ៤ សង្កាត់ : មនោរម្យ សុខដុម ស្ពានមានជ័យ និងរមនា។

២០-ក្រុងកំពង់ឆ្នាំងមាន ៤ សង្កាត់ : ផ្សារឆ្នាំង កំពង់ឆ្នាំង ប្អៀរ និងខ្សាម។

២១-ក្រុងកំពង់ចាម មាន ៤ សង្កាត់ : បឹងកុក កំពង់ចាម សំបួរមាស និងសង្កាត់វាលវង់។

២២-ប្តូរឈ្មោះស្រុកកំពតជាស្រុកទឹកឈូ និងប្តូរឈ្មោះស្រុកកំពង់បាយជាក្រុងកំពត។ មាន ៥ សង្កាត់ : កំពង់កណ្តាល ក្រាំងអំពិល កំពង់បាយ អណ្តូងខ្មែរ និងត្រើយកោះ។

២៣-ក្រុងច្បារមន មាន ៥ សង្កាត់ : សង្កាត់ច្បារមន កណ្តោលដុំ រការធំ សុពណ៌ទេព និងស្វាយក្រវ៉ាន់។

២៤-ក្រុងបាត់ដំបង មាន ១០ សង្កាត់ : សង្កាត់ទួលតាឯក ព្រែកព្រះស្តេច រតនៈ ចំការសំរោង ស្លាកែត ក្តុលដូនទាវ អូរម៉ាល់ វត្តគរ អូរចារ និងស្វាយប៉ោ។

២៥-ក្រុងបានលុង មាន ៤ សង្កាត់ : សង្កាត់កាចាញ ឡាបានសៀក យក្សឡោម និងសង្កាត់បឹងកន្សែង។

២៦-ក្រុងដូនកែវមាន ៣ សង្កាត់ដែលមានសង្កាត់បារាយណ៍ រកាក្នុង និងរកាក្រៅ។

**III- រាជធានីភ្នំពេញមាន ៩ ខណ្ឌ និង៩៦សង្កាត់:**

១- ខណ្ឌចំការមនមាន ១២ សង្កាត់គឺទន្លេបាសាក់ បឹងកេងកង១, ២, ៣ អូឡាំពិក ទួលស្វាយព្រៃទី១ ទួលស្វាយព្រៃទី២ ទំនប់ទឹក ទួលទំពូងទី១ ទួលទំពូងទី២ បឹងត្របែក និងផ្សារដើមថ្កូវ។

២- ខណ្ឌដូនពេញមាន ១១ សង្កាត់គឺផ្សារថ្មីទី១, ២, ៣ បឹងរាំង ផ្សារកណ្ដាលទី១, ២, ចតុមុខ ជ័យជំនះ ផ្សារចាស់ ស្រះចកនិងវត្តភ្នំ។

៣- ខណ្ឌ៧មករាមាន ៨ សង្កាត់ គឺអូរឫស្សី១, ២, ៣, ៤ មនោរម្យ មិត្តភាព វាលវង់ និងបឹងព្រលឹត។

៤- ខណ្ឌទួលគោកមាន ១០ សង្កាត់ គឺផ្សារដេប៉ូ១, ២, ៣ ទឹកល្អក់១, ២, ៣ បឹកកក់១, ២ ផ្សារដើមគរ និងបឹងសាឡាង។

៥- ខណ្ឌដង្កោមាន ១៣ សង្កាត់គឺដង្កោ ពងទឹក ព្រៃវែង ព្រៃស ក្រាំងពង្រ ប្រទះឡាង សាក់សំពៅ ជើងឯក គងនយ ទៀន រលួស ស្ពានថ្ម និងព្រែកកំពឹស។

៦- ខណ្ឌមានជ័យមាន ១២ សង្កាត់ គឺស្ទឹងមានជ័យ បឹងទំពុន ព្រែកប្រា ច្បារអំពៅទី១ ច្បារអំពៅទី២ ចាក់អង្រែលើ ចាក់អង្រែក្រោម និរោធ វាលស្បូវ ព្រែកឯក ក្បាលកោះ និងព្រែកថ្មី។

៧- ខណ្ឌឫស្សីកែវមាន ១១ សង្កាត់ គឺទួលសង្កែ ស្វាយប៉ាក គីឡូម៉ែត្រលេខ៦ ឫស្សីកែវ ព្រែកលៀប ព្រែកតាសេក ជ្រោយចង្វារ ច្រាំងចំរេះទី១ ច្រាំងចំរេះទី២ បាក់ខែង និងកោះដាច់។

៨- ខណ្ឌសែនសុខមាន ៦ សង្កាត់ គឺភ្នំពេញថ្មី ទឹកថ្លា ឃ្មួញ ព្រែកព្នៅ សំរោង ពញាពន់។

៩- ខណ្ឌពោធិ៍សែនជ័យមាន ១៣ សង្កាត់ គឺត្រពាំងក្រសាំង គោករកា ភ្លើងឆេះរទេះ ចោមចៅ កាកាប សំរោងក្រោម ក្រាំងធ្នង់ បឹងធំ ឪឡោក កំបូល កន្ទោក ពន្សាំង និងស្នោរ។

**IV- តារាងសង្ខេប: ចំនួនក្រុង-ស្រុក-ខណ្ឌ-ឃុំ-សង្កាត់តាមរាជធានី-ខេត្ត (ចុងឆ្នាំ២០១១)**

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ឈ្មោះក្រុង | ចំនួនស្រុក-ខណ្ឌ | ចំនួនសង្កាត់ | ចំនួនឃុំ | ផ្ទៃដីឆ្នាំ២០០៨(គ.ម២) |
|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ១-សិរីសោភ័ណ<br>២-ប៉ោយប៉ែត | ៧ | ១០ | ៥៥ | ៦៦៧៩ |
| ២ | បាត់ដំបង | បាត់ដំបង | ១៣ | ១០ | ៩២ | ១១.៧០២ |
| ៣ | កំពង់ចាម | ១-កំពង់ចាម<br>២-សួង | ១៥ | ៦ | ១៦៧ | ៩៧៩៩ |
| ៤ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | ៧ | ៤ | ៦៥ | ៥៥២១ |
| ៥ | កំពង់ស្ពឺ | ច្បារមន | ៧ | ៥ | ៨២ | ៧០១៧ |
| ៦ | កំពង់ធំ | ស្ទឹងសែន | ៧ | ៨ | ៧៣ | ១៣.៨១៤ |
| ៧ | កំពត | កំពត | ៧ | ៥ | ៨៨ | ៤.៨៧៣ |
| ៨ | កណ្ដាល | តាខ្មៅ | ១០ | ៦ | ១២១ | ៣៥៦៤ |
| ៩ | កោះកុង | ខេមរភូមិន្ទ | ៦ | ៣ | ២៦ | ១០.០៩០ |
| ១០ | ក្រចេះ | ក្រចេះ | ៥ | ៥ | ៤១ | ១១.០៩៤ |
| ១១ | មណ្ឌលគិរី | សែនមនោរម្យ | ៤ | ៤ | ១៧ | ១៤.២៨៨ |
| ១២ | ភ្នំពេញ | - | ៩ខណ្ឌ | ៩៦ | - | ២៩៤ |
| ១៣ | ព្រះវិហារ | ព្រះវិហារ | ៧ | ២ | ៤៩ | ១៣.៧៨៨ |
| ១៤ | ព្រៃវែង | ព្រៃវែង | ១២ | ៣ | ១១៣ | ៤.៨៨៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥ | ពោធិសាត់ | ពោធិសាត់ | ៥ | ៧ | ៤២ | ១២.៦៩២ |
| ១៦ | រតនគិរី | បានលុង | ៨ | ៤ | ៤៦ | ១០.៧៨២ |
| ១៧ | សៀមរាប | សៀមរាប | ១១ | ១៣ | ៨៧ | ១០.២៩៩ |
| ១៨ | ព្រះសីហនុ | ព្រះសីហនុ | ៣ | ៥ | ២២ | ១.៩៣៨ |
| ១៩ | ស្ទឹងត្រែង | ស្ទឹងត្រែង | ៤ | ៤ | ៣០ | ១១.០៩២ |
| ២០ | ស្វាយរៀង | ១-ស្វាយរៀង<br>២-បាវិត | ៦ | ១២ | ៦៨ | ២.៩៦៦ |
| ២១ | តាកែវ | ដូនកែវ | ៩ | ៣ | ៩៧ | ៣.៥៦៣ |
| ២២ | ឧត្តរមានជ័យ | សំរោង | ៤ | ៥ | ១៩ | ៦.១៥៨ |
| ២៣ | កែប | កែប | ១ | ៣ | ២ | ៣៣៦ |
| ២៤ | ប៉ៃលិន | ប៉ៃលិន | ១ | ៤ | ៤ | ៨០៨ |
| | បឹងទន្លេសាប | - | - | - | - | ៣.០០០ |
| | **សរុប** | ២៦ | ១៦៨ | ២២៧ | ១.៤០៦ | ១៨១.០៣៥ |

**សំគាល់:** ផ្ទៃដីតាមខេត្ត-រាជធានីមានប្រភពមកពីសៀវភៅជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ បោះពុម្ពខែសីហា ឆ្នាំ២០០៩ ទំព័រ២៨០។

លោកស្រី **គុយ ធល្លា**

## រំលឹកបុត្រធីតា

ធ្វើបុណ្យឱ្យទាន់នៅខែភ្លឺ
ទើបនាំបងប្អូនមករៀបរាប់
ធ្វើបុណ្យដូច្នេះហៅខែល្ងិត
ដល់ពេលស្លាប់ហើយបាននឹកគាត់
ខ្លួនម្តាយឪពុកនៅហូបបាន
យកបាយបន្ទំម្ហូបសម្ល

កុំចាំគាត់ឈឺស្លាប់មរណា
ដល់គុណរូបាអត្តាគាត់។
កាលនៅជីវិតមិនមានមាត់
យកធាតុដាក់វត្តឱ្យស្តាប់ធម៌។
កូនចៅប៉ុន្មានមិនត្រេកអរ
មិនមានត្រេកអរឬជាឡើយ។

**អនោម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុព្វជិកសិក្សាធិការ
គណៈកម្មាធិការកណ្តាល
លេខ : ០១/១៣ គ.ក

# សេចក្តីជូនដំណឹងមរណភាពប្រចាំខែ មករា ឆ្នាំ២០១៣

តាងនាមសមាគមបុព្វជិកសិក្សាទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.
សូមសម្តែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមរំលែកទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ប្រភេទចំណូល | អង្គភាពបម្រើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណភាពសមាជិក | | | | សកម្ម |
| ១ | អ៊ឹង សុខហេង | ៥៨ | ប | ម.ប.ក | អនុវិទ្យាល័យ ចតុមុខ រាជធានីភ្នំពេញ | ១៦.១១.១២ | គាំងបេះដូង | ៣៦៦៣ ភ.ព | ៨៦៣៦ |
| ២ | ឃឹម សុជាតិ | ៤៥ | ប | ម.ប.ក | វិទ្យាល័យ ជម្ពូវ័ន រាជធានីភ្នំពេញ | ២៤.១១.១២ | ជំងឺថ្លើម | ២៤៤៤ ភ.ព | ៨៦៣៧ |
| ៣ | អ៊ឹង ហេង | ៦២ | ប | ម.ប.ក | វិទ្យាល័យ ព្រះយុគន្ធរ រាជធានីភ្នំពេញ | ២៥.១១.១២ | រោគាពាធ | ២៧៦ ភ.ព | ៨៦៣៨ |
| ៤ | អ៊ុន ហ៊ល | ៦០ | ប | បឋម | បឋមសិក្សា សំពៅមាស រាជធានីភ្នំពេញ | ០៣.១២.១២ | លើសឈាម | ១៥២៣ ភ.ព | ៨៦៣៩ |
| ៥ | ទឹម ឃី | ៨៣ | ប | បឋម | និវត្តជន ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ | ២១.១១.១២ | ជរាពាធ | ២០៤៥ ក្រ.ច | ៨៦៤០ |
| ៦ | យុន យូម៉ុ | ៦០ | ស | បឋម | បឋម ខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម | ០២.១១.១២ | មហារីក | ១៧១១ ក.ច | ៨៦៤១ |
| ៧ | ស៊េត ថាយ | ៥៨ | ប | បឋម | អនុវិ.ហស.កោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម | ១៥.១១.១២ | លើសឈាម | ៤០៧២ ក.ច | ៨៦៤២ |
| ៨ | សុក សំ | ៦១ | ប | បឋម | និវត្តជន បឋម តាំងគោក ស្រុកចំការលើ ខេត្តកំពង់ចាម | ២១.១០.១២ | រោគាពាធ | ៥៨៣១ ក.ច | ៨៦៤៣ |
| ៩ | ម៉ៅ សាមាន | ៥៩ | ប | ម.ប.ក | អនុវិ.រំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង | ០១.១១.១២ | លើសឈាម | ៥៨៣ ព.វ | ៨៦៤៤ |
| ១០ | ខេត ប៊ិច | ៤៤ | ស | បឋម | បឋម តាកែវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ១៦.១១.១២ | រោគាពាធ | ១៩៨៣ ព.វ | ៨៦៤៥ |
| ១១ | ជឹម ជ | ៥៥ | ប | បឋម | បឋមព្រហារ ស្រុកមេសាង ខេត្តព្រៃវែង | ៣១.១០.១២ | រោគាពាធ | ៦៧៤៧ ព.វ | ៨៦៤៦ |
| ១២ | ឯក គី | ៨០ | ប | បឋម | និវត្តជន អនុវិ. ប្រធាតុ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ២៦.១០.១២ | ជរាពាធ | ៦៨៥៧ ព.វ | ៨៦៤៧ |
| ១៣ | ឈឿង លីហេង | ៤២ | ប | បឋម | បឋម កំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ១៣.១១.១២ | គ្រោះថ្នាក់ចរាចរ | ៧២០៩ ព.វ | ៨៦៤៨ |
| ១៤ | ឃុត សុខខេង | ៤០ | ប | ម.ប.ក | អនុ. អង្គសាយ បរសេដ្ឋ ខេត្តកំពង់ស្ពឺ | ០៥.១១.១២ | រោគាពាធ | ៣០៨៧ ក.ស្ព | ៨៦៤៩ |
| ១៥ | អុន ឈឿន | ៦៧ | ប | បឋម | និវត្តជន ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ១៤.១០.១២ | រោគាពាធ | ២៣៨៤ ក.ស្ព | ៨៦៥០ |
| ១៦ | ឡាង អាត | ៤៤ | ប | បឋម | បឋម ទួលត្រាច ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ០៣.១១.១២ | រោគាពាធ | ០៤១៧ ក.ស្ព | ៨៦៥១ |
| ១៧ | ប៉េង ហេង | ៥៧ | ប | បឋម | បឋម ស្រះធុល ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ | ៣០.០៩.១២ | រោគាពាធ | ១៩១៦ ក.ស្ព | ៨៦៥២ |
| ១៨ | សៀង ប៊ុនឡៅ | ៣៩ | ប | បឋម | បឋម អង្គលំទង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ០១.១០.១២ | រោគាពាធ | ០២៩៤ ក.ស្ព | ៨៦៥៣ |
| ១៩ | ម៉ែន សំអុល | ៣៧ | ប | បឋម | បឋមតាទួន បរសេដ្ឋ ខេត្តកំពង់ស្ពឺ | ០៥.១១.១២ | រោគាពាធ | ៣០៦៦ ក.ស្ព | ៨៦៥៤ |
| ២០ | សំ ធឿន | ៦០ | ប | បឋម | និវត្តជន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ០៤.១០.១២ | រោគាពាធ | ២៣៧៩ ក.ស្ព | ៨៦៥៥ |
| ២១ | ឆង ទិមល | ៥៦ | ប | បឋម | បឋម បុប្ផារតី បរសេដ្ឋ ខេត្តកំពង់ស្ពឺ | ០៨.១១.១២ | រោគាពាធ | ២៧៥៦ ក.ស្ព | ៨៦៥៦ |
| ២២ | ទូច ដាណុល | ៣២ | ប | បឋម | បឋមសត្វពង ស្រុកឈូក ខេត្តកំពត | ២៥.១០.១២ | ជំងឺសរសៃឈាមខួរ | ៥០៧១ ក.ព | ៨៦៥៧ |
| ២៣ | ម៉ឿង ឡាង | ៦០ | ប | ម.ទ.ក | និវត្តជន វិទ្យាល័យ ហ.ស ឈូក ស្រុកឈូក ខេត្តកំពត | ១២.១០.១២ | រោគាពាធ | ២៤៤៧ ក.ព | ៨៦៥៨ |
| ២៤ | ឃាន ឆយ | ៧២ | ប | គ្រូ. | និវត្តជន បឋម កូនសត្វ ស្រុកទឹកឈូ ខេត្តកំពត | ០៨.១០.១២ | រោគាពាធ | ៣១៤ ក.ព | ៨៦៥៩ |
| ២៥ | ស៊ីទូ ប៊ូផាន់ | ៦៤ | ស | បឋម | និវត្តជន បឋមបន្ទាយចាស់ ក្រុងសៀមរាប ខេត្តសៀមរាប | ២២.១០.១២ | មហារីក | ៣៦៩ ស.រ | ៨៦៦០ |
| ២៦ | វៀម វណ្ណារ៉ា | ២៩ | ប | ម.ទ.ក | សាលាគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប | ៣១.១០.១២ | គ្រោះថ្នាក់ចរាចរ | ៧៤៩២ ស.រ | ៨៦៦១ |
| ២៧ | ស្វាយ រិន | ៧៧ | ប | គ្រូ. | និវត្តជន បឋមត្រួច ស្រុកជីក្រែង ខេត្តសៀមរាប | ០៣.១១.១២ | រោគាពាធ | ២៣១៧ ស.រ | ៨៦៦២ |
| ២៨ | ស្រី វ៉ន | ៤៣ | ប | បឋម | បឋមស្វា ស្រុកពួក ខេត្តសៀមរាប | ១០.១១.១២ | គាំងបេះដូង | ២៥៨៨ ស.រ | ៨៦៦៣ |
| ២៩ | កែវម៉ម សុភញ្ញ៉ា | ៦៤ | ស | គ្រូ. | និវត្តជន បឋមបន្ទាយចាស់ ក្រុងសៀមរាប ខេត្តសៀមរាប | ២៦.១០.១២ | ទឹកនោមផ្អែម | ៦៤៣ ស.រ | ៨៦៦៤ |
| ៣០ | ប៊ុន តុងសុភាពត្ត័ | ៤២ | ស | បឋម | បឋមវត្តកំផែង ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ០១.១១.១២ | រោគាពាធ | ៦៦៥ ប.ប | ៨៦៦៥ |
| ៣១ | វ៉ាយ មួន | ៦៨ | ប | បឋម | និវត្តជន ស្រុកមោងឫស្សី ខេត្តបាត់ដំបង | ១៥.១១.១២ | រោគាពាធ | ៣៩៤០ ប.ប | ៨៦៦៦ |
| ៣២ | ណុប ហេង | ៦៦ | ប | បឋម | និវត្តជន ស្រុកបាសាក្រឡ ខេត្តបាត់ដំបង | ១៩.១១.១២ | រោគាពាធ | ៦៤៣៨ ប.ប | ៨៦៦៧ |
| ៣៣ | សំ សុភី | ២៥ | ស | បឋម | បឋមស្លកប្រាក ស្រុករុក្ខគិរី ខេត្តបាត់ដំបង | ២០.១១.១២ | ទឹកនោមផ្អែម | ១០៩៦៤ ប.ប | ៨៦៦៨ |
| ៣៤ | ជួប សិទ្ធិ | ៦៤ | ប | បឋម | និវត្តជន ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ២៥.១១.១២ | រោគាពាធ | ៥៤៥៤ ប.ប | ៨៦៦៩ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៥ | ជាន ម៉ាលី | ៧៤ | ស | បឋម | និវត្តជន ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ០៧.១២.១២ | រោគាពាធ | ៤៣២៣ ប.ប | ៨៦៧០ |
| ៣៦ | ហ៊ឹម ឡាំ | ៦៤ | ប | បឋម | និវត្តជន ស្រុកមោងឫស្សី ខេត្តបាត់ដំបង | ០៧.១២.១២ | រោគាពាធ | ៤១២៨ ប.ប | ៨៦៧១ |
| ៣៧ | ជ្រាំង សំអ៊ាន | ៦៧ | ប | បឋម | និវត្តជន ស្រុករមាសហែក ខេត្តស្វាយរៀង | ១៦.១០.១២ | ជរាពាធ | ១៥២២ ស្វ.រ | ៨៦៧២ |
| ៣៨ | វត្ថី ពុទ្ធារី | ៤៤ | ស | ម.ប.ភ | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ខេត្តស្វាយរៀង | ២១.១០.១២ | មហារីកក្រពះ | ៧៥៧ ស្វ.រ | ៨៦៧៣ |
| ៣៩ | អុង ភាន | ៣៨ | ប | បឋម | សាលាបឋមសិក្សាជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង | ២៥.១០.១២ | គាំងបេះដូង | ៥៩០ ស្វ.រ | ៨៦៧៤ |
| ៤០ | ព្រហ្ម ឈឿន | ៦១ | ប | ប.ប.ភ | និវត្តជន ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ១០.១១.១២ | ទឹកនោមផ្អែម | ១៦៤៨ ស្វ.រ | ៨៦៧៥ |
| ៤១ | ចឹម ចន្ទធួន | ៥១ | ស | បឋម | សាលាបឋមសិក្សាស្វាយ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ១១.១១.១២ | តម្រងនោម | ១៦១៧ ស្វ.រ | ៨៦៧៦ |
| ៤២ | ព្រំ អាន | ៦៥ | ប | បឋម | និវត្តជន ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ១៣.១១.១២ | ជរាពាធ | ៣២២ ស្វ.រ | ៨៦៧៧ |
| ៤៣ | អ៊ុក សាឌន | ៥៧ | ប | បឋម | សាលាបឋមសិក្សា ចំបក់កោង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | ១៦.១១.១២ | ខ្យល់គរ | ៣៥៥ ស្វ.រ | ៨៦៧៨ |
| ៤៤ | យូ នៅ | ៦៦ | ប | គ្រូ. | និវត្តជន ស្រុកព្រៃកប្បាស ខេត្តតាកែវ | ០៥.១១.១២ | ជរាពាធ | ៤៨៦៥ ស្វ.រ | ៨៦៧៩ |
| ៤៥ | ខ្មៅ ញ៉ាន | ៦៧ | ប | គ្រូ. | និវត្តជន ស្រុកទ្រាំង ខេត្តតាកែវ | ១៧.១១.១២ | រោគាពាធ | ៥២៨ ស្វ.រ | ៨៦៨០ |
| ៤៦ | ផៃ ឡើម | ៦៨ | ប | គ្រូ. | និវត្តជន ស្រុកគិរីវង់ ខេត្តតាកែវ | ០៥.១១.១២ | លង់ទឹក | ៤០១៣ ស្វ.រ | ៨៦៨១ |
| ៤៧ | គង់ សុភាព | ៦១ | ស | គ្រូ. | និវត្តជន ក្រុងដូនកែវ ខេត្តតាកែវ | ៣០.១១.១២ | រោគាពាធ | ៣៥៨១ ស្វ.រ | ៨៦៨២ |
| ៤៨ | ចែត ថុល | ៨១ | ប | គ្រូ. | និវត្តជន បឋមស្វាយមាស ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល | ៣០.១០.១២ | រោគាពាធ | ៣៦២៦ ក.ណ | ៨៦៨៣ |
| ៤៩ | អ៊ឹង លី | ៦០ | ប | បឋម | បឋម ហ.ស សូរភី ស្រុកស្អាង ខេត្តកណ្ដាល | ២៤.១០.១២ | រោគាពាធ | ៥៨៣៦ ក.ណ | ៨៦៨៤ |
| ៥០ | អាំ ហ៊ុង | ៥៣ | ប | បឋម | បឋមឫស្សីជ្រោយ ស្រុកស្អាង ខេត្តកណ្ដាល | ២០.១០.១២ | រោគាពាធ | ២០៦១ ក.ណ | ៨៦៨៥ |
| ៥១ | ហង សាម៉ន | ៦៦ | ប | គ្រូ. | និវត្តជន ការិ.អយក ស្រុកអង្គស្នួល ខេត្តកណ្ដាល | ២៨.១០.១២ | រោគាពាធ | ៥៣០៧ ក.ណ | ៨៦៨៦ |
| ៥២ | កួង សុន | ៧១ | ប | គ្រូ. | និវត្តជន ការិ.អយក ស្រុកអង្គស្នួល ខេត្តកណ្ដាល | ០៣.១១.១២ | រោគាពាធ | ៤៨៨៤ ក.ណ | ៨៦៨៧ |
| ៥៣ | កង សេងហាក់ | ៤៤ | ប | បឋម | បឋមកោះរកា ស្រុកមុខកំពូល ខេត្តកណ្ដាល | ១០.១១.១២ | រោគាពាធ | ១០៨៤ ក.ណ | ៨៦៨៨ |
| ៥៤ | ពេជ្រ ខេត | ៧៤ | ប | គ្រូ. | និវត្តជន បឋមវត្តកោះធំ ស្រុកកោះធំ ខេត្តកណ្ដាល | ១៤.១០.១២ | រោគាពាធ | ១៩៩ក.ណ | ៨៦៨៩ |
